គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

គណៈកម្មាធិការប្រតិបត្តិ នៃ គ.អ.ប.ខ កំពង់ចាម

# សៀវភៅណែនាំ

# ការអនុវត្តន៍គម្រោងសេវាកម្មបែបសហគមន៍

អនុវត្តសាកល្បង

គម្រោងសេវាកម្មឆ្នាំ២០១០ របស់មន្ទីរកសិកម្មខេត្ត ខណ្ឌរដ្ឋបាលជលផលកំពង់ចាម

និងស្រុកគោលដៅទាំង១៣ នៃគម្រោងសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុក

354.968 IMP

កំពង់ចាម ខែ មិថុនា ឆ្នាំ ២០១០

បណ្ណាល័យ
គ.ជ.អ.ប

# មាតិកាអត្ថបទ

**អារម្ភកថា**

**I. គោលបំណង** 01

**II. ការចងក្រង និងបង្កើតសហគមន៍** 0១

2.1. ការជ្រើសរើសសមាជិក 0១

2.2. ការរៀបចំរចនាសម្ព័ន្ធសហគមន៍ 0៤

2.3. ការតាក់តែងលក្ខន្តិកៈ 0៦

2.4. ការអនុម័ត និងផ្សព្វផ្សាយ 0៦

**III. ការគាំទ្រដំណើរការផលិតកម្ម** 0៧

3.1. ដើមទុនរបស់គម្រោង 0៧

3.2. ដើមទុនរបស់កសិករ 0៨

**IV. ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាព** 0៩

4.1. មូលដ្ឋានបច្ចេកទេស និងបំណិន 0៩

4.2. ការគ្រប់គ្រង ដឹកនាំ និងចាត់ចែងសហគមន៍ ១0

4.3. នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសហគមន៍ ១0

4.4. ការទំនាក់ទំនងទីផ្សារ និងការធ្វើជំនួញខ្នាតតូច ១១

4.5. ការគ្រប់គ្រងឥណទាន និងកំចីខ្នាតតូច ១១

4.6. ក្របខ័ណ្ឌច្បាប់ជំនួញខ្នាតតូច ១១

**V. ការពង្រឹងនិរន្តរភាពសហគមន៍** ១២

5.1. ការរៀបចំផែនការពង្រឹងសហគមន៍ ១២

5.2. ការគ្រប់គ្រង និងចាត់ចែងថវិកាសហគមន៍ ១២

5.3. ការប្រឹក្សាយោបល់ និងការសម្របសម្រួល ១៣

5.4. ការដោះស្រាយទំនាស់ ១៣

5.5. ការតាមដាន និងវាយតម្លៃ ១៤

**VI. ការធ្វើនិយ័តកម្ម និងការពង្រីកទំហំសាលភាព** ១៤

6.1. ដំណើរការចុះបញ្ជីពាណិជ្ជកម្ម ១៤

6.2. ការផ្ទេរសិទ្ធិគ្រប់គ្រងពេញលេញ ១៤

354.968
IMP
library.ncdd.gov.kh
002888



sh: Training

6.3. ការពង្រីកវិសាលភាពសហគមន៍ ១៥
VII. **ការគ្រប់គ្រងបញ្ហាប្រឈម និងហានិភ័យ** ១៥
7.1. កសិករមិនចូលរួមក្នុង គម្រោងបែបនេះ ១៥
7.2. កសិករមិនអាចសងប្រាក់ ដើមទុនត្រឡប់មកវិញ ១៦
7.3. សហគមន៍មិនដំណើរ ការ និងមិនរីកចំរើន ១៦
7.4. មិនមានការគាំទ្រ ដើម្បីបន្តនិរន្តរភាព ១៦
7.5. ការិយាល័យជំនាញថ្នាក់ស្រុកមិនអាចអនុវត្តបាន ១៦
7.6. មិនមានតម្លាភាព និងគណនេយ្យភាពនៅក្នុងការគ្រប់គ្រង ដឹកនាំ និងចាត់ចែងសហគមន៍ ១៦
7.7. កសិករទទួលប្រាក់ទុនពីគម្រោងមិនព្រមទិញសម្ភារៈ និងពូជសម្រាប់ផលិតកម្ម ១៧
VIII. **សុពលភាពនៃសេចក្តីណែនាំ** ១៧

**ឧបសម្ព័ន្ធនានា**

ទម្រង់ទី ១ : បញ្ជីឈ្មោះកសិករស្ម័គ្រចិត្តចូលជាសមាជិកសហគមន៍
ទម្រង់ទី ២.ក : បញ្ជីសំណួរអង្កេតតាមគ្រួសារ
ទម្រង់ទី ២.ខ : តារាងវាយតម្លៃគ្រួសារក្រីក្រ និងគ្រួសារធូរធារដែលបានសម្ភាសន៍
ទម្រង់ទី ៣ : បញ្ជីឈ្មោះសមាជិកសហគមន៍ពេញសិទ្ធិ និងត្រៀមបំរ៉ុង
ទម្រង់ទី ៤ : សេចក្តីសម្រេចស្តីពីការបង្កើតក្រុមប្រឹក្សាភិបាលសហគមន៍
ទម្រងទី ៥ : សេចក្តីសម្រេចស្តីពីការបង្កើតគណៈគ្រប់គ្រងសហគមន៍
ទម្រង់ទី ៦ : លក្ខន្តិកៈសហគមន៍
ទម្រង់ទី ៧.ក : កិច្ចសន្យាផ្តល់ដើមទុនដល់សមាជិកសហគមន៍ (សម្រាប់ស្រុក)
ទម្រង់ទី ៧.ខ : កិច្ចសន្យាផ្តល់ដើមទុនដល់សមាជិកសហគមន៍ (សម្រាប់មន្ទីរ)
ទម្រង់ទី ៨ : តារាងបញ្ជីពូជ និងសម្ភារៈសម្រាប់ផលិតកម្ម
ទម្រង់ទី ៩.ក : លិខិតបញ្ជប់កិច្ចសន្យារវាងសមាជិកសហគមន៍ និងគណៈកម្មការគ្រប់គ្រងគម្រោង (ស្រុក)
ទម្រង់ទី ៩.ខ : លិខិតបញ្ជប់កិច្ចសន្យារវាងសមាជិកសហគមន៍ និងគណៈកម្មការគ្រប់គ្រងគម្រោង (មន្ទីរ)
ទម្រង់ទី ១០.ក : អនុសារណៈយោគយល់ (សម្រាប់ស្រុក)
ទម្រង់ទី ១០.ខ : អនុសារណៈយោគយល់ (សម្រាប់មន្ទីរ)
ទម្រង់ទី ០ : វិក្កយបត្រទទួលប្រាក់សំណងដើមទុនផលិតកម្ម

# អារម្ភកថា

ផ្តើមចេញពីការពិចារណាលើមេរៀនពិសោធន៍អវិជ្ជមាននាឆ្នាំកន្លងមក លទ្ធផលសិក្សាផលត្រឡប់ពីការវិនិយោគ និងការវាយតម្លៃផលប៉ះពាល់នៃគម្រោងគ្រប់គ្រងធនធានធម្មជាតិ និងលើកស្ទួយជីវភាពរស់នៅចំពោះសេដ្ឋកិច្ច-សង្គមជនបទ របស់ម្ចាស់ជំនួយដានីដា និងកង្វះខាតសេចក្តីណែនាំលម្អិត នៃការអនុវត្តន៍គម្រោងសេវាកម្ម គណៈកម្មាធិការប្រតិបត្តិ នៃ គ.អ.ជ.ខ កំពង់ចាម សហការជាមួយទីប្រឹក្សា ភី.អេស.ឌី.ឌី បានផ្តួចផ្តើមគំនិតថ្មីមួយគឺ **ការអនុវត្តន៍គម្រោងសេវាកម្មបែបសហគមន៍** ក្នុងគោលបំណងធានាឱ្យសម្រេចបានលទ្ធផល ដែលប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងមាននិរន្តរភាព ពិសេសផ្តល់ឱកាស ដល់គ្រួសារក្រីក្រទទួលបានប្រយោជន៍ច្រើនពីការអភិវឌ្ឍន៍មូលដ្ឋាន តាមរយៈគម្រោងនានា របស់ គ.ជ.អ.ប ដែលគាំទ្រមូលនិធិពីម្ចាស់ជំនួយ ដានីដា ។ ម្យ៉ាងទៀត ដើម្បីជម្រុញសេដ្ឋកិច្ចជនបទឱ្យមានកំណើនជាបន្តបន្ទាប់ ការអនុវត្តន៍គម្រោងបែបសហគមន៍ ដែលមានកសិករធូរធារ មធ្យម និងក្រីក្រចូលរួម និងបង្កើតនូវបរិយាកាសប្រាស្រ័យទាក់ទងគ្នាល្អ ជួយគ្នាទៅវិញទៅមក នឹងជម្រុញផលិតកម្មរបស់គាត់បានចូលទៅកាន់ទីផ្សារពិតប្រាកដ។ ដូចគ្នាដែរ គណៈកម្មាធិការប្រតិបត្តិ នៃ គ.អ.ជ.ខ កំពង់ចាម ក៏មានបំណងកែសម្រួលយុទ្ធសាស្ត្រអនុវត្តគម្រោងសេវាកម្មនានា របស់មន្ទីរ និងស្រុកនៅឆ្នាំ២០១០ និងពង្រឹងនូវយន្តការតាមដាន និងវាយតម្លៃ ពិសេសគណនេយ្យភាព និងភាពច្បាស់លាស់របស់ភ្នាក់ងារអនុវត្តគម្រោង ឬភ្នាក់ងារផ្តល់សេវា ដែលជាមន្ត្រីជំនាញការិយាល័យនៅថ្នាក់ស្រុក ។

សៀវភៅនេះត្រូវបានតាក់តែងឡើងសម្រាប់ប្រើជាគោលការណ៍កំរិតថ្នាក់ខេត្ត ដែលបានពិភាក្សា និងពិគ្រោះយោបល់យ៉ាងលម្អិតនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិចំនួន២លើកគឺ លើកទី១នៅថ្ងៃទី២ ខែមិថុនា និងលើកទី២ នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១០ ដោយមានការចូលរួមយោបល់ពីឯកឧត្តមសមាជិកក្រុមប្រឹក្សាខេត្ត ថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិ មន្ត្រីផ្នែកទាំង៤ របស់ គ.ប្រ នៃ គ.អ.ជ.ខ លោក-លោកស្រីអភិបាល និងអភិបាលរងស្រុក និងលោក-លោកស្រីប្រធាន ឬអនុប្រធានការិយាល័យជំនាញពាក់ព័ន្ធនៅថ្នាក់ស្រុកទាំង១៣ និងទីប្រឹក្សា ភី.អេស.ឌី.ឌី ទាំងអស់ ។ ខ្លឹមសារ នៃសៀវភៅណែនាំនេះគ្របដណ្តប់លើចំណុចធំៗចំនួន៨និងចំណុចតូចៗចំនួន២៧ដែលពាក់ព័ន្ធនឹងនិតិវិធី និងដំណើរការអនុវត្តគម្រោងសេវាកម្មបែបសហគមន៍នេះដោយអមមកជាមួយនូវទម្រង់គំរូចំនួន១៥ សម្រាប់ប្រើប្រាស់ជាឯកសារជំនួយស្មារតី និងមគ្គុទ្ទេសក៍ ក្នុងការអនុវត្តន៍គម្រោងប្រកបដោយរលូន និងត្រឹមត្រូវ ។

ដោយសារការតាក់តែងសេចក្តីណែនាំនេះមិនត្រូវបានចំណាយពេលសមស្រប ហេតុដូច្នេះសេចក្តីណែនាំនេះប្រាកដជានឹងមានចំណុចខ្វះខាត ដែលតម្រូវឱ្យធ្វើការកែសម្រួលនៅឆ្នាំបន្ទាប់ទៀត ដើម្បីធ្វើឱ្យមានភាពស៊ីសង្វាក់ និងសុក្រិត្យភាព រវាងសេចក្តីណែនាំ និងស្ថានភាពពិតនៅមូលដ្ឋាននីមួយៗ ចៀសវាង

នូវហានីភ័យណាមួយកើតឡើងដោយថាហេតុពីការអនុវត្តន៍សេចក្តីណែនាំនេះ ។ គណៈកម្មាធិការប្រតិបត្តិ នៃ គ.អ.ជ.ខ កំពង់ចាមស្នើដល់លោក_លោកស្រី ដែលជាអ្នកអនុវត្តគម្រោងផ្ទាល់នៅមូលដ្ឋានចងក្រងនូវមេរៀនពិសោធន៍នានាទាំងវិជ្ជមាន និងអវិជ្ជមាន ហើយផ្ញើរជូនមកគណៈកម្មាធិការប្រតិបត្តិខេត្ត សម្រាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការកែតម្រូវ ឬកែសម្រួល ឬបន្ថែមខ្លឹមសារលើសេចក្តីណែនាំនេះនៅឆ្នាំ២០១១ ។ ម្យ៉ាងទៀត គណៈកម្មាធិការប្រតិបត្តិខេត្តជឿជាក់ថា ការអនុវត្តន៍សេចក្តីណែនាំនេះនៅឆ្នាំដំបូងនឹងជួបការលំបាក និងបញ្ហាប្រឈមនានា ។ ហេតុដូច្នេះហើយ លោក_លោកស្រីត្រូវទំនាក់ទំនងមកគណៈកម្មាធិការប្រតិបត្តិខេត្ត ដើម្បីស្នើសុំជំនួយបច្ចេកទេស និងការបកស្រាយបំភ្លឺបន្ថែម ចៀសវាងការអនុវត្តន៍ផ្ទុយពីសេចក្តីណែនាំនេះ ដែលនាំដល់ការខូចខាតលទ្ធផលគម្រោង ពិសេសភាពបរាជ័យ និងការខាតបង់ថវិកាម្ចាស់ជំនួយ ។ ទាំងមន្ត្រី នៃគណៈកម្មាធិការប្រតិបត្តិខេត្ត និងទីប្រឹក្សា ភី.អេស.ឌី.ឌី រង់ចាំឆ្លើយតបនូវការស្នើសុំពីលោក_លោកស្រី និងទទួលរាល់មតិយោបល់ស្ថាបនា អនុសាសន៍នានា សម្រាប់ធ្វើឱ្យគោលនយោបាយថ្មីស្រឡាងនេះកាន់តែល្អប្រសើរ និងអាចអនុវត្តដោយរលូននៅឆ្នាំបន្តបន្ទាប់ខាងមុខទៀត ។ ដូច្នេះ សេចក្តីណែនាំនេះនឹងត្រូវប្រកាស និងដាក់ឱ្យប្រើប្រាស់សាកល្បងនៅឆ្នាំ២០១០ ***សម្រាប់មន្ទីរកសិកម្មខេត្ត ខណ្ឌរដ្ឋបាលជលផលកំពង់ចាម និងបណ្តាស្រុកគោលដៅទាំង១៣ នៃគម្រោងពង្រឹងតួនាទីថ្នាក់ស្រុក*** ។ រាល់ការអនុវត្តន៍សេចក្តីណែនាំនេះសម្រាប់គម្រោងមួយចំនួនដូចជា សហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍ទេសចរណ៍ធម្មជាតិ និងវប្បធម៌ សហគមន៍គ្រប់គ្រងធនធានធម្មជាតិនិងអភិរក្សជីវចំរុះ គម្រោងសេវាកម្មរបស់ឃុំ និងបណ្តាខេត្តដទៃទៀតមិនត្រូវបានអនុញ្ញាតិឡើយ ។

គណៈកម្មាធិការប្រតិបត្តិ នៃ គ.អ.ជ.ខ កំពង់ចាមសង្ឃឹមយ៉ាងមុតមាំថា មន្ទីរ និងស្រុកគោលដៅទាំង១៣ នៃគម្រោងសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុកផ្តល់កិច្ចសហការយ៉ាងល្អប្រសើរ តាមខ្លឹមសារដូចបានបញ្ជាក់ជូនខាងលើ និងខិតខំប្រឹងប្រែងអនុវត្តសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាព និងទទួលបានជោគជ័យ និងផ្លែផ្កាដ៏ប្រសើរបំផុត សម្រាប់គាំទ្រគោលនយោបាយកំណែទម្រង់រដ្ឋបាលឯកភាព នៅថ្នាក់ក្រោមជាតិ និងក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរបស់រាជរដ្ឋាភិបាលកម្ពុជា ។

កំពង់ចាម ថ្ងៃទី ..២៣.. ខែ ..មិថុនា... ឆ្នាំ ២០១០

**ប្រធានគណៈកម្មាធិការប្រតិបត្តិ**

ហ៊ុន_ណេង

# គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
# គណៈកម្មាធិការប្រតិបត្តិ នៃ គ.អ.ជ.ខ កំពង់ចាម

## សេចក្តីណែនាំ
## ដំណើរការ និងនីតិវិធីអនុវត្តគម្រោងសេវាកម្មបែបសហគមន៍

## I. គោលបំណង

- បង្កើនប្រសិទ្ធភាព ប្រសិទ្ធផល និងនិរន្តភាព នៃលទ្ធផលគម្រោងសេវាកម្មនានា
- ពង្រឹងគណនេយ្យភាពរបស់អ្នកផ្តល់សេវា និងអ្នកទទួលផលសម្រាប់ការអភិវឌ្ឍន៍សហគមន៍
- ធ្វើឱ្យប្រាកដនូវដំណើរការអនុវត្តគម្រោងសេវាកម្មនានារបស់មន្ទីរ និងស្រុកដែលប្រើប្រាស់ថវិកា គ.ជ.អ.ប តាមរយៈ គ.ប្រ នៃ គ.អ.ជ.ខ ។
- ពង្រឹងប្រព័ន្ធ និងយន្តការតាមដាន និងវាយតម្លៃគម្រោងដើម្បីធានាឱ្យមានអភិបាលកិច្ចល្អ
- បង្កើនឱកាសសម្រាប់គ្រួសារក្រីក្រទទួលបានផលប្រយោជន៍ពីគម្រោង និងការបង្កើតមុខរបរច្បាស់លាស់សម្រាប់អ្នកក្រឆ្ពោះទៅកំណើនសេដ្ឋកិច្ចគ្រួសារប្រកបដោយចិរភាព ។

## II. ការចងក្រង និងបង្កើតសហគមន៍

### *២.១ ការជ្រើសរើសសមាជិក*

ការជ្រើសរើសសមាជិកសហគមន៍ត្រូវធ្វើឡើង តាមរយៈការប្រជុំផ្សព្វផ្សាយ នៅតាមភូមិគោលដៅរបស់គម្រោង ដោយមានការចូលរួមពីប្រជាពលរដ្ឋ ដែលមានស្ថានភាពគ្រួសារក្នុងជីវិតខុសៗគ្នា (អ្នកធូរធារ អ្នកមធ្យម អ្នកក្រ និងអ្នកក្របំផុត) និងអាជ្ញាធរភូមិ និងឃុំ ។ បើសិនមានអង្គការសហគមន៍មូលដ្ឋានកំពុងប្រតិបត្តិការនៅទីនោះ គួរត្រូវបានអញ្ជើញចូលរួម ដើម្បីដើរតួជាអ្នកសង្កេតការណ៍ និងការផ្តល់យោបល់នានាចំពោះដំណើរការជ្រើសរើសនេះ ។ ចំពោះអ្នកក្រ និងអ្នកក្របំផុតគួរអញ្ជើញចូលរួមទាំងអស់ ដោយផ្អែកលើបញ្ជីគ្រួសារក្រីក្រ ដែលជាលទ្ធផល នៃការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ របស់មន្ទីរផែនការខេត្ត នោះបើសិនភូមិ និងឃុំគោលដៅគម្រោងជាភូមិ និងឃុំគោលដៅ ដែលបានអនុវត្តគម្រោងកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្ររួច នៅឆ្នាំ ២០០៨ ឬ ២០០៩ ។

ភ្នាក់ងារអនុវត្តន៍ ឬអ្នកផ្តល់សេវាសហការជាមួយគណៈកម្មការគ្រប់គ្រងគម្រោង (ចំពោះគម្រោងស្រុក) ឬអាជ្ញាធរមូលដ្ឋាន (ចំពោះគម្រោងមន្ទីរ) ត្រូវផ្តល់សារយ៉ាងច្បាស់លាស់ស្តីពីគោល

ការណ៍ ដំណើរការ និតិវិធី និងលក្ខណៈវិនិច្ឆ័យ នៃការអនុវត្តន៍គម្រោងសេវាកម្មបែបសហគមន៍ ដូចជា សហគមន៍ផលិតកម្មដំណាំស្រូវ សហគមន៍ចិញ្ចឹមមាន់ សហគមន៍ចិញ្ចឹមជ្រូក ... ។ល។ ដល់អ្នកចូលរួមឱ្យបានយល់ដឹង ដើម្បីធ្វើជាមូលដ្ឋានក្នុងការពិចារណាសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តចូលរួមក្នុងគម្រោងនោះ ។ ក្រោយពីការផ្តល់ព័ត៌មានស្តីពីការអនុវត្តន៍គម្រោងនៅក្នុងភូមិ ឃុំ នោះរួច ភ្នាក់ងារអនុវត្តន៍ ឬអ្នកផ្តល់សេវាត្រូវរៀបចំបញ្ជីឈ្មោះសមាជិកសហគមន៍បណ្តោះអាសន្ន **(សូមមើលទម្រង់ទី១)** ដើម្បីចុះឈ្មោះអ្នកស្ម័គ្រចិត្តចូលរួមជាសមាជិកសហគមន៍នោះ ។ ចំពោះការចុះបញ្ជីឈ្មោះអ្នកស្ម័គ្រចិត្តត្រូវធ្វើឡើង ដោយមិនកំណត់ចំនួនច្បាស់លាស់ឡើយគឺ ផ្អែកតាមគោលការណ៍ស្ម័គ្រចិត្ត ។ ដូច្នេះ មានអ្នកស្ម័គ្រចិត្តប៉ុន្មានក៏ដោយត្រូវតែចុះក្នុងបញ្ជីនោះទាំងអស់ ដោយមិនប្រកាន់ជាតិសាសន៍ ពណ៌សម្បុរ ភេទ និងឋានៈក្នុងសង្គម ។

នៅពេលរៀបចំបញ្ជីឈ្មោះអ្នកស្ម័គ្រចិត្តរួចហើយ ភ្នាក់ងារអនុវត្តន៍ ឬអ្នកផ្តល់សេវាត្រូវរៀបចំចុះអង្កេតលើគ្រួសារទាំងនោះ តាមរយៈវិធីសាស្រ្តសម្ភាសន៍ និងសង្កេតតាមគ្រួសារ **(សូមមើលទម្រង់ទី២.៣)** ។ ជាគោលការណ៍ទាំងចំនួនគ្រួសារក្រីក្រដែលបាន និងមិនបានធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រូវតែជ្រើសរើសឱ្យបានពាក់កណ្តាល នៃសមាជិកសរុបរបស់សហគមន៍ ។ រីឯពាក់កណ្តាលទៀតអាចបញ្ចូលគ្រួសារអ្នកធូរធារ និងអ្នកមធ្យមតាមគោលការណ៍ស្ម័គ្រចិត្ត ។ ដូច្នេះ ដើម្បីអាចគិតចំនួនសមាជិកសហគមន៍ នៅក្នុងបញ្ជីឈ្មោះផ្លូវការចុងក្រោយ ឱ្យស្របតាមចំនួនគ្រោងក្នុងផែនការថវិកា នៃអនុកិច្ចសន្យាប្រចាំឆ្នាំរបស់មន្ទីរ និងស្រុក (ឧ. គម្រោងសហគមន៍ចិញ្ចឹមមាន់នៅក្នុង ស្រុកបាធាយត្រូវបានគ្រោងចំនួន៥សហគមន៍ និងក្នុង១សហគមន៍មានសមាជិកចំនួន១៥នាក់) ភ្នាក់ងារអនុវត្តន៍ ឬអ្នកផ្តល់សេវាត្រូវចុះអង្កេតគ្រួសារទាំងអស់ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះបណ្តោះអាសន្ន ។

គោលបំណង នៃការចុះអង្កេតនេះគឺ ដើម្បីរៀបចំព័ត៌មានលំអិត របស់គ្រួសារទាំងនោះ សម្រាប់ប្រើប្រាស់ជាមូលដ្ឋាន ក្នុងការកំណត់ចំនួនសមាជិកសហគមន៍ជាក់លាក់ សម្រាប់គម្រោងសេវាកម្ម ដែលផ្តល់ឱ្យដោយមន្ទីរ និងស្រុកព្រោះចំនួនអ្នកស្ម័គ្រចិត្ត និងចំនួនគិតនៅក្នុងផែនការមានភាពខុសគ្នា ។ ដូច្នេះ ដើម្បីផ្តល់លទ្ធភាពក្នុងការជ្រើសរើសសមាជិកសហគមន៍ ឱ្យស្របតាមគោលការណ៍ខាងលើ ភ្នាក់ងារអនុវត្តន៍ ឬអ្នកផ្តល់សេវាត្រូវប្រើប្រាស់លក្ខណៈវិនិច្ឆ័យពីរប្រភេទផ្សេងគ្នាខាងក្រោមជាមូលដ្ឋានក្នុងការពិចារណា និងការសម្រេចចិត្ត ដោយមានការចូលរួមផ្តល់យោបល់ពីគណៈកម្មការគ្រប់គ្រងគម្រោង (ចំពោះគម្រោងស្រុក) អាជ្ញាធរមូលដ្ឋាន (ចំពោះគម្រោងមន្ទីរ) តាមរយៈកិច្ចប្រជុំដែលរៀបចំនៅថ្នាក់ឃុំ ដោយមានការចូលរួមសង្កេតការណ៍ពីមន្រ្តីស្រុក និងអង្គការសហគមន៍មូលដ្ឋាន (បើមាន)។ ដើម្បីជំនួយដល់ការជ្រើសរើសសមាជិកសហគមន៍

ប្រព្រឹត្តិទៅដោយរលូន សូមអ្នកផ្តល់សេវា ឬភ្នាក់ងារអនុវត្តគម្រោងប្រើ**ទម្រង់ទី២.១** និងចម្លងចូលទៅក្រដាសផ្ទាំងធំ ដើម្បីវាយតម្លៃគ្រួសារដែលបានសម្ភាសន៍ ធៀបនឹងលក្ខណៈវិនិច្ឆ័យ ដោយញែកជាពីរផ្សេងគ្នា សម្រាប់ដំណើរការជ្រើសរើសនេះ ។ លក្ខណៈវិនិច្ឆ័យទាំងពីរប្រភេទនោះរួមមាន :

**(ក). សម្រាប់គ្រួសារអ្នកធូរធារ និងគ្រួសារអ្នកមធ្យម**

១. គ្រួសារដែលបានផ្តល់សមាជិករបស់ខ្លួនជាអចិន្ត្រៃយ៍ជាសមាជិកសហគមន៍

២. គ្រួសារមានមុខរបរស្រាប់ស្របនឹងបរិបទសហគមន៍ (ដាំបន្លែ ចិញ្ចឹមមាន់...)

៣. គ្រួសារដែលត្រូវបានអ្នកភូមិផ្សេងទៀតគោរពស្រឡាញ់ និងផ្តល់ទំនុកចិត្ត

៤. គ្រួសារដែលមានឆន្ទះជួយអ្នកដទៃ មានភាពស្មោះត្រង់ និងស្រឡាញ់យុត្តិធម៌

៥. គ្រួសារដែលមានផ្ទះស្ថិតនៅជិតៗគ្នា មិនឆ្ងាយពីគ្នាលើសពីមួយគីឡូម៉ែត្រ

៦. គ្រួសារមានសមត្ថភាពទាំងស្មារតី ធនធាន ចំណេះដឹង (អក្ខរកម្ម) និងសម្ភារៈផលិតកម្ម

៧. គ្រួសារមានកំលាំងពលកម្មគ្រប់គ្រាន់ និងកាយសម្បទាមាំមួន

៨. គ្រួសារដែលមិនជប់ជល់នឹងល្បែង គ្រឿងញៀន ស្រា និងមិនមានប្រវត្តិជាចោរ ឬជាបក្ខពួកចោរ ចោរប្លន់ និងមិនមែនជាគ្រួសារទំនើង ឬមុខសញ្ញាអង្កេតរបស់ប៉ូលីស ។

៩. គ្រួសារមានដីសម្រាប់ផលិតកម្ម (ចំពោះផលិតកម្មដំណាំស្រូវ និងការចិញ្ចឹមត្រី) និងមានគំនិតច្នៃប្រឌិតខ្លួនឯង ។ ចំពោះផលិកម្មក្រៅពីនេះមិនតម្រូវឱ្យមានដីផលិតកម្មទេ។

**(ខ). សម្រាប់គ្រួសារក្រីក្រខាំងខាត និងមិនបានធ្វើអត្តសញ្ញាណកម្ម**

១. គ្រួសារដែលបានផ្តល់សមាជិករបស់ខ្លួនជាអចិន្ត្រៃយ៍ជាសមាជិកសហគមន៍

២. គ្រួសារដែលត្រូវបានអ្នកភូមិផ្សេងទៀតគោរពស្រឡាញ់ និងផ្តល់ទំនុកចិត្ត

៣. គ្រួសារដែលមានឆន្ទះជួយអ្នកដទៃ មានភាពស្មោះត្រង់ និងស្រឡាញ់ យុត្តិធម៌

៤. គ្រួសារដែលមានផ្ទះស្ថិតនៅជិតៗគ្នា មិនឆ្ងាយពីគ្នាលើសពីមួយគីឡូម៉ែត្រ

៥. គ្រួសារមានកំលាំងពលកម្មគ្រប់គ្រាន់ និងកាយសម្បទាមាំមួន

៦. គ្រួសារដែលមិនជប់ជល់នឹងល្បែង គ្រឿងញៀន ស្រា និងមិនមានប្រវត្តិជាចោរ ឬជាបក្ខពួកចោរ ចោរប្លន់ និងមិនមែនជាគ្រួសារទំនើង ឬមុខសញ្ញាអង្កេតរបស់ប៉ូលីស ។

៧. គ្រួសារមានដីសម្រាប់ផលិតកម្ម (ចំពោះផលិតកម្មដំណាំស្រូវ និងការចិញ្ចឹមត្រី) និងមានគំនិតច្នៃប្រឌិតខ្លួនឯង ។ ចំពោះផលិកម្មក្រៅពីនេះមិនតម្រូវឱ្យមានដីផលិតកម្មទេ។

៨. គ្រួសារដែលមិនជាប់បំណុល ឬបើជំពាក់ កំរិតបំណុលមិនត្រូវលើសពី ៤២០.០០០រៀល ឬស្មើនឹង ១០០ ដុល្លារអាមេរិក ។ ក្នុងករណីជំពាក់ជាសម្ភារៈដូចជាស្រូវ អង្ករ សៀងផ្សេងៗ ឬសម្ភារៈមានតម្លៃដទៃទៀតត្រូវគិតជាសាច់ប្រាក់មិនឱ្យលើសពីតម្លៃខាងលើ ។

ក្រោយពីអង្គប្រជុំខាងលើនេះ បញ្ជីឈ្មោះសមាជិកសហគមន៍ពេញសិទ្ធិ និងបញ្ជីឈ្មោះសមាជិកសហគមន៍ត្រៀមបំរ៉ុង (យ៉ាងច្រើន៦គ្រួសារ ក្នុងនោះគ្រួសារអ្នកក្រមានពាក់កណ្ដាល) ត្រូវបានរៀបចំឡើងឱ្យបានច្បាស់លាស់ ដោយមានចុះហត្ថលេខាយល់ព្រមពីប្រធានគណៈកម្មការគ្រប់គ្រងគម្រោង (ចំពោះគម្រោងរបស់ស្រុក) ឬមេឃុំ (ចំពោះគម្រោងរបស់មន្ទីរ) អមដោយកំណត់ហេតុអង្គប្រជុំ (**សូមមើលទម្រង់ទី៣**) ។ ក្រោយពីកិច្ចការទាំងនេះត្រូវបានរៀបចំរួច គណៈកម្មការគ្រប់គ្រងគម្រោង ឬមេឃុំរៀបចំផ្សព្វផ្សាយជាសាធារណៈ និងផ្ដល់ព័ត៌មានឱ្យបានច្បាស់លាស់ដល់គ្រួសារ ដែលត្រូវបានជ្រើសរើសទាំងអស់នោះលើកលែងគ្រួសារត្រៀមបំរ៉ុង ឱ្យបានដឹង និងត្រៀមសម្រាប់ការងារបន្តបន្ទាប់ទៀត ។ ការផ្សព្វផ្សាយព័ត៌មាននេះត្រូវបិទនៅបញ្ជរព័ត៌មានរបស់សាលាឃុំ និងតាមរយៈមេភូមិ ។ បញ្ជីឈ្មោះសមាជិកសហគមន៍ជាផ្លូវការនឹងត្រូវបញ្ជូនមកស្រុកចំនួន ១ច្បាប់ និងគណៈកម្មាធិការប្រតិបត្តិ នៃ គ.អ.ជ.ខ ចំនួន១ច្បាប់ ។ ដូច្នេះ បញ្ជីឈ្មោះច្បាប់ដើមត្រូវរៀបចំចំនួន៤ច្បាប់ ដើម្បីអាចចែករំលែកព័ត៌មានទៅអ្នកពាក់ព័ន្ធខាងលើ ប៉ុន្តែចំពោះមន្ទីររៀបចំតែ៣ច្បាប់ប៉ុណ្ណោះដោយមិនចាំបាច់បញ្ជូនទៅស្រុកឡើយ ។

### ***២.២ ការរៀបចំរចនាសម្ព័ន្ធសហគមន៍***

ដើម្បីឱ្យសហគមន៍ដំណើរការទៅដោយរលូន ចាំបាច់ត្រូវតែមានរចនាសម្ព័ន្ធបឋមមួយដែលមិនមានភាពស្មុគស្មាញ សម្រាប់ការងារគ្រប់គ្រង ដឹកនាំ និងចាត់ចែងកិច្ចការសហគមន៍ ។ រចនាសម្ព័ន្ធអាចនឹងកែប្រែ និងធ្វើវិសោធនកម្ម នៅពេលសហគមន៍នោះមានភាពរឹងមាំ និងអាចដំណើរការបានដោយឯករាជ្យ ដោយអនុលោមតាមលក្ខន្តិកៈ និងច្បាប់ផ្សេងៗទៀតរបស់សហគមន៍ ។ នៅចំពោះមុខនេះ ភ្នាក់ងារអនុវត្តន៍ ឬអ្នកផ្ដល់សេវាត្រូវសហការជាមួយគណៈកម្មការគ្រប់គ្រងគម្រោង និងគណៈកម្មការបច្ចេកទេសស្រុករៀបចំ និងបង្កើតរចនាសម្ព័ន្ធសហគមន៍មួយ ដែលមាន (១) ក្រុមប្រឹក្សាភិបាលសហគមន៍ និង (២) គណៈគ្រប់គ្រងសហគមន៍ ។

ក្រុមប្រឹក្សាភិបាលសហគមន៍ នៅដំណាក់កាលដំបូងនេះ ត្រូវបានបង្កើតឡើងតាមការចាត់តាំង ដោយគណៈកម្មការបច្ចេកទេសស្រុក ដែលមានសុពលភាពត្រឹម៣ឆ្នាំ ។ នៅដំណាក់កាលទី២ ក្រុមប្រឹក្សាភិបាលនេះនឹងត្រូវបង្កើតឡើង តាមការបោះឆ្នោតបែបប្រជាធិបតេយ្យ និងទទួលស្គាល់ដោយក្រុមប្រឹក្សាឃុំ-សង្កាត់ ។ នីតិវិធីនេះនឹងត្រូវបានចែងលំអិតនៅក្នុងលក្ខន្តិកៈ ហើយតួនាទី និងភារកិច្ចទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលសហគមន៍នឹងត្រូវបានចែងនៅក្នុងសេចក្ដីសម្រេចតែងតាំងក្រុមប្រឹក្សាភិបាល របស់គណៈកម្មការបច្ចេកទេសស្រុក (**សូមមើលទម្រង់ទី៤**) និងលក្ខន្តិកៈ ។ សមាសភាពរបស់ក្រុមប្រឹក្សាភិបាលមានយ៉ាងច្រើន៥នាក់រួមមាន :

- ប្រធានក្រុមប្រឹក្សាភិបាល (គួរជ្រើសរើសពីសមាជិកគណៈកម្មការបច្ចេកទេសស្រុកប៉ុន្តែ មិនពាក់ព័ន្ធមន្ត្រីរបស់គណៈកម្មាធិការប្រតិបត្តិ) ។
- អនុប្រធានក្រុមប្រឹក្សាភិបាល (គួរជ្រើសរើសពីប្រធាន ឬអនុប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអន្តរឃុំ-សង្កាត់) ។
- សមាជិកក្រុមប្រឹក្សាភិបាល (គួរជ្រើសរើសប្រធានភូមិ ឬអនុភូមិ)
- សមាជិកក្រុមប្រឹក្សាភិបាល (គួរជ្រើសរើសប្រធាន ឬអនុប្រធានអង្គការមូលដ្ឋាន)
- សមាជិកក្រុមប្រឹក្សាភិបាល (គួរជ្រើសរើសប្រធានសហគមន៍ដើរតួជាលេខាធិការ)

គណៈគ្រប់គ្រងសហគមន៍បង្កើតឡើងដោយការបោះឆ្នោតបែបប្រជាធិបតេយ្យ ។ បេក្ខជនឈរឈ្មោះត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះសមាជិកសហគមន៍ ដែលបានជ្រើសរើស និងទទួលស្គាល់ដោយគណៈកម្មការគ្រប់គ្រងគម្រោងអន្តរឃុំ-សង្កាត់តាមគោលការណ៍ស្ម័គ្រចិត្តក្នុងនោះពាក់កណ្តាលនៃបេក្ខភាពឈរឈ្មោះបោះឆ្នោតគឺជាស្ត្រី ។ មានតែសមាជិកសហគមន៍ប៉ុណ្ណោះ ដែលជាម្ចាស់សំលេងឆ្នោតពេញសិទ្ធិ សម្រាប់ការបោះឆ្នោត ។ ចំពោះក្រុមប្រឹក្សាភិបាល គណៈកម្មការគ្រប់គ្រងគម្រោង អ្នកផ្តល់សេវា ឬភ្នាក់ងារអនុវត្តន៍គម្រោង គណៈកម្មការបច្ចេកទេសស្រុក មន្ត្រីស្រុក អាជ្ញាធរភូមិ និងឃុំ ប្រជាពលរដ្ឋផ្សេងទៀតមិនមានសិទ្ធិបោះឆ្នោតឡើយ ។ ប៉ុន្តែអ្នកទាំងនោះជាអ្នកចូលរួមសង្កេតការណ៍ និងផ្តល់មតិយោបល់លើដំណើរការបោះឆ្នោត ឱ្យសម្រេចបានប្រកបដោយសេរី យុត្តិធម៌ ប្រជាធិបតេយ្យ និងអាចទទួលយកបាន ។ បេក្ខជនណាមួយដែលទទួលបានសំលេងឆ្នោតត្រឹមត្រូវច្រើនជាងគេនឹងត្រូវបានតែងតាំងជាប្រធាន ហើយបេក្ខជនមានសំលេងឆ្នោតត្រឹមត្រូវច្រើនបន្ទាប់នឹងត្រូវបានតែងតាំងជាអនុប្រធាន ។ ចំពោះ តួនាទីផ្សេងទៀតនឹងត្រូវប្រគល់ជូនបេក្ខជនមានសំលេងឆ្នោតច្រើនបន្តបន្ទាប់គ្នា ដោយមានការពិគ្រោះយោបល់ពីប្រធានសហគមន៍ និងប្រធានក្រុមប្រឹក្សាភិបាលសហគមន៍ ដើម្បីសម្រេចលើតួនាទី របស់បេក្ខជន ដែលនៅសេសសល់ទាំងនោះ ។ ក្រោយពីការបោះឆ្នោតមួយសប្តាហ៍ ហើយមិនមានការតវ៉ា ឬបណ្តឹងទេ ប្រធានក្រុមប្រឹក្សាភិបាលសហគមន៍ត្រូវចេញសេចក្តីសម្រេចតែងតាំងគណៈគ្រប់គ្រងសហគមន៍ (**សូមមើលទម្រង់ទី៥**) ដែលមានសមាសភាព៦រូបដូចខាងក្រោម :

- ប្រធានសហគមន៍ (បេក្ខជនដែលទទួលបានសំលេងឆ្នោតត្រឹមត្រូវច្រើនទី១)
- អនុប្រធានសហគមន៍ (បេក្ខជនដែលទទួលបានសំលេងឆ្នោតត្រឹមត្រូវច្រើនទី២)
- ប្រធានរដ្ឋបាល និងហិរញ្ញវត្ថុ (កំណត់ដោយប្រធានសហគមន៍ និងក្រុមប្រឹក្សាភិបាល)
- ប្រធានផ្នែកផលិតកម្ម និងទំនាក់ទំនងទីផ្សារ (កំណត់ដោយប្រធានសហគមន៍ និងក្រុមប្រឹក្សាភិបាល) ។

- លេខាធិការ (កំណត់ដោយប្រធានសហគមន៍ និងក្រុមប្រឹក្សាភិបាល)
- ហិរញ្ញិក និងបេឡាករ (កំណត់ដោយប្រធានសហគមន៍ និងក្រុមប្រឹក្សាភិបាល)

តួនាទី និងភារកិច្ចទទួលខុសត្រូវរបស់គណៈគ្រប់គ្រងសហគមន៍ និងសមាជិកនីមួយៗនឹងត្រូវបានចែងលំអិតនៅក្នុងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងលក្ខន្តិកៈរបស់សហគមន៍ ។

### *២.៣ ការតាក់តែងលក្ខន្តិកៈ*

លក្ខន្តិកៈរបស់សហគមន៍នឹងត្រូវបានតាក់តែងដោយមានការចូលរួមផ្ដល់យោបល់ពីសមាជិកសហគមន៍ទាំងអស់ និងក្រុមប្រឹក្សាភិបាល រួមទាំងគណៈគ្រប់គ្រងសហគមន៍ ក្រោមការជួយសម្របសម្រួល និងគាំទ្របច្ចេកទេសពីអ្នកផ្ដល់សេវា ឬភ្នាក់ងារអនុវត្តគម្រោង និងគណៈកម្មការគ្រប់គ្រងគម្រោងអន្តរឃុំ-សង្កាត់ ។ តាមរយៈសេចក្ដីណែនាំនេះ ឯកសារលក្ខន្តិកៈគំរូ (**សូមមើលឧបសម្ព័ន្ធទី៦**) នឹងត្រូវបានរៀបចំជាសេចក្ដីព្រាង ហើយឯកសារនេះនឹងត្រូវបំពេញបន្ថែមនូវល័ក្ខខ័ណ្ឌ និងព័ត៌មានចាំបាច់នានាទៅតាមសំណើ និងការផ្ដល់យោបល់ពីសមាជិកសហគមន៍ ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងសហគមន៍ ។ កិច្ចការនេះអាចសម្រេចបានយ៉ាងហោចណាស់ត្រូវចំណាយពេលពី២ទៅ៣ថ្ងៃ ទើបអាចតាក់តែងលក្ខន្តិកៈមួយ ដែលមានន័យពេលលេញ និងអាចអនុវត្តបាន ពិសេសការទទួលយកបានដោយសមាជិកសហគមន៍ ព្រោះអ្នកទាំងនោះជាអ្នកទទួលផលប្រយោជន៍ ។ ទោះជាយ៉ាងណា លក្ខន្តិកៈនេះមិនតម្រូវឱ្យរៀបចំពេញលក្ខណៈ និងសព្វគ្រប់ជ្រៅជ្រះឡើយ ព្រោះនេះជាពេលវេលាចង្អៀតសម្រាប់ការបង្កើតសហគមន៍ ។ ហេតុដូច្នេះ លក្ខន្តិកៈនឹងតម្រូវឱ្យមានការធ្វើវិសោធនកម្មបន្ថែមទៀតនៅឆ្នាំទី២ ឬទី៣ ឬនៅពេលសហគមន៍រឹងមាំ ។

### *២.៤ ការអនុម័ត និងផ្សព្វផ្សាយ*

ក្រោយពីបញ្ចប់ទាំងស្រុង និងព្រមព្រៀងលើលក្ខខ័ណ្ឌនានា នៃលក្ខន្តិកៈ គណៈគ្រប់គ្រងសហគមន៍ សហការជាមួយអ្នកផ្ដល់សេវា ឬភ្នាក់ងារអនុវត្តត្រូវរៀបចំប្រជុំមួយ ដើម្បីឆ្លងសេចក្ដីព្រាងលក្ខន្តិកៈជាមួយក្រុមប្រឹក្សាភិបាលសហគមន៍ ។ កិច្ចប្រជុំនេះនឹងតម្រូវឱ្យមានការចូលរួមសង្កេតការណ៍ពីគណៈកម្មការគ្រប់គ្រងគម្រោង និងគណៈកម្មការបច្ចេកទេស ដើម្បីធានាឱ្យការអនុម័តលើលក្ខន្តិកៈនេះប្រកបដោយតម្លាភាព និងគណនេយ្យភាព ។ ឯកសារលក្ខន្តិកៈ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនឹងតម្រូវឱ្យចងក្រងជាសៀវភៅ និងបោះពុម្ពផ្សាយដល់សមាជិកសហគមន៍ ក្រុមប្រឹក្សាភិបាល គណៈកម្មការគ្រប់គ្រងគម្រោង គណៈកម្មការបច្ចេកទេសស្រុក និងគណៈកម្មការប្រតិបត្តិ នៃ គ.អ.ជ.ខ ។ ចំនួនសៀវភៅលក្ខន្តិកៈដែលត្រូវបោះពុម្ពផ្សាយត្រូវផ្អែកលើផែនការថវិកាដែលបានគ្រោងនៅក្នុងអនុកិច្ចសន្យាមន្ទីរ និងស្រុកនីមួយៗ ។

## III. ការគាំទ្រដំណើរការផលិតកម្ម

### *៣.១ ដើមទុនរបស់គម្រោង*

នៅក្នុងផែនការថវិកានៃអនុកិច្ចសន្យារបស់មន្ទីរនិងស្រុកនីមួយៗ ដើមទុនផលិតកម្មសម្រាប់គាំទ្រដល់កសិករនៅឆ្នាំដំបូងត្រូវបានគ្រោងក្នុងកំរិតពី ២៣ដុល្លារ ទៅដល់១៨៥ដុល្លារ ផ្អែកទៅតាមប្រភេទផលិតកម្ម និងថវិកាគ្រោងរបស់មន្ទីរ និងស្រុកដែលដាក់ស្នើមក គ.ប្រ នៃ គ.អ.ជ.ខ ។ ការផ្តល់ថវិកាដើមទុនដល់កសិករត្រូវធ្វើឡើង តាមរយៈការចុះកិច្ចសន្យា រវាងគណៈកម្មការគ្រប់គ្រងគម្រោងអន្តរឃុំ-សង្កាត់ និងគ្រួសារកសិករផ្ទាល់ ដោយមានសាក្សីចំនួន២នាក់គឺ (១) ប្រធានសហគមន៍ និង (២) គណៈកម្មការបច្ចេកទេសស្រុក ។ បើសិនកិច្ចសន្យាធ្វើឡើង រវាងគណៈកម្មការគ្រប់គ្រងគម្រោងអន្តរឃុំ និងប្រធានសហគមន៍ សាក្សី២សម្រាប់កិច្ចសន្យានេះគឺ (១) ប្រធានក្រុមប្រឹក្សាភិបាលសហគមន៍ និង (២) គណៈកម្មការបច្ចេកទេសស្រុក (**សូមមើលទម្រង់ទី៧.ក**) ។ ចំពោះគម្រោងរបស់មន្ទីរ ការចុះកិច្ចសន្យាផ្តល់ដើមទុនឱ្យកសិករត្រូវធ្វើឡើងរវាងប្រធានមន្ទីរ និងកសិករផ្ទាល់ដោយមានសាក្សីពីរនាក់គឺ (១) ប្រធានក្រុមប្រឹក្សាភិបាល និង (២) មេឃុំ ឬចៅសង្កាត់ (**សូមមើលទម្រង់ទី៧.ខ**) ។

ថវិកាដើមទុនដែលផ្តល់ឱ្យកសិករត្រូវបានគិតជាសាច់ប្រាក់សុទ្ធជាដុល្លារ ឬរៀល ដោយផ្អែកតាមអត្រាប្តូរប្រាក់ទីផ្សារ នៅក្នុងថ្ងៃចុះកិច្ចសន្យា ។ ថវិកាដើមទុននេះនឹងត្រូវបានប្រើប្រាស់សម្រាប់ទិញពូជ និងសម្ភារៈផលិតកម្មចាំបាច់ ដែលត្រូវបានលម្អិតនៅក្នុងតារាងឧបសម្ព័ន្ធ នៃកិច្ចសន្យាផ្តល់ដើមទុនដល់កសិករ (**សូមមើលទម្រង់ទី៨**) ដើម្បីបញ្ជាក់ដល់កសិករថា នេះគឺជាកាតព្វកិច្ច ដែលគាត់ត្រូវតែបំពេញដាច់ខាត ក្នុងការប្រើប្រាស់ថវិកាដើមទុននេះ ដោយមិនអនុញ្ញាត្តិឱ្យគាត់ប្រើប្រាស់ថវិកាដើមទុននេះផ្ទុយពីតារាងឧបសម្ព័ន្ធនេះឡើយ ។ ការកំណត់ពូជ និងសម្ភារៈផលិតកម្មចាំបាច់ត្រូវធ្វើឡើងដោយផ្អែកលើប្រភេទផលិតកម្ម តម្រូវការនៃទំហំផលិតកម្ម និងតម្លៃទីផ្សារក្រោមជំនួយបច្ចេកទេសពីភ្នាក់ងារអនុវត្តន៍ ឬអ្នកផ្តល់សេវា ប្រកបដោយតម្លាភាព និងមិនកេងបន្លំឡើយ ។ ដើមទុនដែលផ្តល់ដល់កសិករនៅឆ្នាំដំបូងមិនត្រូវបានគិតការប្រាក់ឡើយ ។ ចាប់ពីឆ្នាំទី២តទៅ ដើមទុននេះនឹងត្រូវចាត់ចែងដោយសហគមន៍ផ្ទាល់ ក្រោមការសម្របសម្រួលពីក្រុមប្រឹក្សាភិបាលសហគមន៍ ក្រុមប្រឹក្សាឃុំ និងគណៈកម្មការបច្ចេកទេសស្រុក តាមរូបភាពជាឥណទានខ្នាតតូចដោយមាន ឬគ្មានការប្រាក់ អាស្រ័យលើការព្រមព្រៀង របស់សមាជិកសហគមន៍ និងដោយមានចែងនៅក្នុងលក្ខន្តិកៈ ។ មានតែសមាជិកសហគមន៍ប៉ុណ្ណោះដែលមានសិទ្ធិពេញលេញក្នុងការទទួលបានប្រាក់កំចីពីប្រធានសហគមន៍ សម្រាប់ផលិតកម្មនៅឆ្នាំបន្តបន្ទាប់ រីឯប្រជាពលរដ្ឋផ្សេងទៀតដែលមិនមែនជាសមាជិកសហគមន៍នេះមិនត្រូវបានផ្តល់សិទ្ធិឡើយ ។

ដើម្បីធានាឱ្យសហគមន៍មាននិរន្តភាព និងអាចបន្តផលិតកម្មរបស់ខ្លួននៅឆ្នាំបន្តបន្ទាប់ទៀត ថវិកាដើមទុនដែលផ្តល់ឱ្យកសិករនៅឆ្នាំដំបូងត្រូវតែប្រមូលត្រឡប់មកវិញ ក្រោយពីការប្រមូលផលភ្លាមពីផលិតកម្មរបស់គាត់ ដោយផ្អែកទៅតាមកិច្ចសន្យាផ្តល់ដើមទុន ។ គណៈគ្រប់គ្រងសហគមន៍មានតួនាទីក្នុងការប្រមូលថវិកានោះពីកសិករ រួមទាំងខ្លួនឯងផង ដោយសហការជាមួយគណៈកម្មការគ្រប់គ្រងគម្រោង និងអ្នកផ្តល់សេវា ឬភ្នាក់ងារអនុវត្តន៍ ។ ថវិកាដែលប្រមូលបានពីកសិករទាំងអស់រួមទាំងសមាជិកគណៈគ្រប់គ្រងសហគមន៍ទាំងអស់ត្រូវដាក់បញ្ចូលទៅក្នុងគណនីសហគមន៍នៅក្នុងធនាគារឯកជននៅមូលដ្ឋាន (ឧ.ធនាគារ អេស៊ីលីដា)។ ដើម្បីបញ្ជាក់ថា កសិករបានសងដើមទុនមកកម្មវិធីវិញគ្រប់ចំនួន គណៈកម្មការគ្រប់គ្រងគម្រោងអន្តរឃុំត្រូវចេញលិខិតបញ្ជាក់កិច្ចសន្យាផ្តល់ទុន (**សូមមើលទម្រង់ទី៩.ក**) ។ ចំពោះគម្រោងមន្ទីរ លិខិតបញ្ជាក់កិច្ចសន្យាត្រូវធ្វើឡើងដោយប្រធានមន្ទីរ (**សូមមើលទម្រង់ទី៩.ខ**) ។

ក្រោយពីថវិកាដើមទុនត្រូវបានប្រមូលពីកសិករគ្រប់ចំនួន គណៈគ្រប់គ្រងសហគមន៍ត្រូវរៀបចំពិធីផ្ទេរសិទ្ធិគ្រប់គ្រងថវិកា រវាងគណៈកម្មការគ្រប់គ្រងគម្រោងអន្តរឃុំ-សង្កាត់ និងប្រធានសហគមន៍ ក្រោមអធិបតីភាពលោកអភិបាលស្រុក ឬអភិបាលរងស្រុក ដែលជាប្រធាន ឬអនុប្រធានគណៈកម្មការបច្ចេកទេសស្រុក និងក្រុមប្រឹក្សាភិបាលសហគមន៍ ។ ការផ្ទេរសិទ្ធិគ្រប់គ្រងនឹងត្រូវធ្វើឡើង តាមរយៈអនុស្សារណៈយោគយល់ រវាងគណៈកម្មការគ្រប់គ្រងគម្រោងអន្តរឃុំ-សង្កាត់ និងប្រធានសហគមន៍ (**សូមមើលទម្រង់ទី១០.ក**) ។ ចំពោះគម្រោងរបស់មន្ទីរ អនុស្សារណៈត្រូវធ្វើឡើងរវាងប្រធានមន្ទីរ និងប្រធានសហគមន៍ (**សូមមើលទម្រង់ទី១០.ខ**) ។ ការប្រើប្រាស់ថវិកានេះបន្តទៅទៀតនឹងត្រូវបានចែងលម្អិតនៅក្នុងលក្ខន្តិកៈសហគមន៍ ។ ចំពោះការបើកគណនីនៅក្នុងធនាគារឯកជននឹងត្រូវអនុលោមទៅតាមនិតិវិធី និងច្បាប់របស់ធនាគារនោះ ។

### *៣.២ ដើមទុនរបស់កសិករ*

ដោយថវិកាដើមទុនមានកំណត់ កសិករត្រូវមានដើមទុន របស់ខ្លួនបន្ថែមទៀត ឬសម្ភារៈផ្សេងៗទៀត សម្រាប់ចូលរួមក្នុងផលិតកម្មរបស់ខ្លួនទៅតាមតម្រូវការចាំបាច់ ។ សមាជិកសហគមន៍មានសិទ្ធិកំណត់ទំហំផលិតកម្មរៀងៗខ្លួន ដោយផ្អែកលើទុន ដែលបានផ្តល់ដោយកម្មវិធី និងទុនផ្ទាល់ខ្លួនឯងដែលមានស្រាប់ ។ ឧ. នៅក្នុងសហគមន៍ចិញ្ចឹមជ្រូក កសិករនីមួយៗតម្រូវឱ្យមានជ្រូក២ (ឈ្មោល១ និងញី១) សម្រាប់ផលិតកម្មនៅឆ្នាំដំបូង ប៉ុន្តែកសិករខ្លះអាចចិញ្ចឹមជ្រូកច្រើនជាងពីរបាន លុះត្រាតែកសិករនោះមានដើមទុនផ្ទាល់ខ្លួនឯង សម្រាប់បំពេញបន្ថែមទៅលើផលិតកម្មនោះ ។ ចំណុចនេះអាចធ្វើបានចំពោះតែកសិករមានជីវភាពធូរធារ ឬមធ្យមតែប៉ុណ្ណោះ ។ រីឯកសិករក្រីក្រមិនមានលទ្ធភាពពង្រីកផលិកម្មរបស់ខ្លួនឡើយ ។

វិធីសាស្ត្រមួយទៀត ដើម្បីបង្កើនប្រាក់ទុនរបស់សហគមន៍ រួមជាមួយថវិកាដើមទុនដែលប្រមូលពីកសិករក្រោយប្រមូលផល និងត្រូវបានផ្ទេរឱ្យសហគមន៍ ដោយគណៈកម្មការគ្រប់គ្រងគម្រោងអន្តរឃុំ-សង្កាត់ សហគមន៍អាចកំណត់អត្រាពន្ធលើប្រាក់ចំណេញពីផលិតកម្ម របស់គ្រួសារនីមួយៗ ដើម្បីបង់ចូលជាថវិកាសហគមន៍ សម្រាប់ចំណាយលើការជួលអ្នកបច្ចេកទេសនៅឆ្នាំបន្ទាប់ និងកិច្ចការរដ្ឋបាលរបស់សហគមន៍ ដើម្បីធានាដល់ការងារគ្រប់គ្រង ដឹកនាំ និងចាត់ចែងសហគមន៍ ។ ល័ក្ខខ័ណ្ឌនេះត្រូវតែមានការព្រមព្រៀងពីសមាជិកសហគមន៍ទាំងអស់ ទើបអាចធ្វើទៅបាន ដោយមិនមានការបង្ខិតបង្ខំឡើយ ហើយចំណុចនេះនឹងត្រូវចែងនៅក្នុងលក្ខន្តិកៈសហគមន៍ ។

## IV. ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាព

### *៤.១ មូលដ្ឋានបច្ចេកទេស និងបំណិន*

ដើម្បីអាចឱ្យកសិករដំណើរការផលិតកម្មបាន ចាំបាច់មូលដ្ឋានបច្ចេកទេស និងបំណិន នៃផលិតកម្មនីមួយៗពាក់ព័ន្ធនឹងសហគមន៍នោះដូចជា បច្ចេកទេសចិញ្ចឹមជ្រូក បច្ចេកទេសចិញ្ចឹមមាន់ បច្ចេកទេសធ្វើស្រែប្រពលវប្បកម្ម បច្ចេកទេសដាំបន្លែ ឬកសិកម្មចំរុះត្រូវបានផ្តល់ដល់កសិករ ដែលជាសមាជិកសហគមន៍ទាំងនោះ ។ លើសពីនេះទៀត មិនត្រឹមតែផ្តល់បច្ចេកទេសដូចបានបញ្ជាក់ខាងលើប៉ុណ្ណោះទេ គឺត្រូវបន្ថែមបច្ចេកទេសដែលពាក់ព័ន្ធមួយចំនួនទៀត ដែលជាកញ្ចប់បច្ចេកទេសមួយអាចធានាឱ្យកសិករដំណើរការផលិតកម្មរបស់ខ្លួនមានប្រសិទ្ធភាពនិងប្រសិទ្ធផល ។ ឧ. កសិករទទួលបានបច្ចេកទេសធ្វើស្រែប្រពលវប្បកម្ម ដូច្នេះក្រៅពីបច្ចេកទេសនេះក៏ត្រូវបង្រៀនកសិករឱ្យចេះផលិតពូជ និងការជ្រើសរើសពូជសម្រាប់តម្រូវការទីផ្សារជាដើម ។ ការចិញ្ចឹមត្រី និងជ្រូកត្រូវតែភ្ជាប់មកជាមួយនូវបច្ចេកទេសផលិតចំណី ។ល។ និង ។ល។ ហេតុដូច្នេះ អ្នកផ្តល់សេវា ឬភ្នាក់ងារអនុវត្តគម្រោងត្រូវរៀបចំផែនការបណ្តុះបណ្តាលកសិករ តាមជំនាញបច្ចេកទេសឱ្យច្បាស់លាស់ និងសមស្របតាមទីផ្សារ ដើម្បីធ្វើឱ្យកសិករជឿទុកចិត្ត និងការទទួលផលពីផលិតកម្មដ៏សមស្របតាមការវិនិយោគរបស់គាត់ ។ នៅឆ្នាំទី១ និងទី២ ការបណ្តុះបណ្តាលបច្ចេកទេសជាមូលដ្ឋានទាំងនេះពិតជាចាំបាច់ណាស់ សម្រាប់ផលិតកម្មរបស់គាត់ ហើយអ្នកផ្តល់សេវា ឬភ្នាក់ងារអនុវត្តគម្រោងត្រូវតែជ្រើសរើសពូជ ឬប្រភេទផលិតកម្មណាដែលសមស្របទៅនឹងទីផ្សារទាំងក្នុងស្រុក និងក្រៅស្រុក ។ ឧ. ស្ពៃ ខាត់ណា ត្រសក់ ស្ពៃក្តោប ...គឺជាផលិតផលកសិកម្មមួយដែលទីផ្សារត្រូវការច្រើនជារៀងរាល់ថ្ងៃ ហើយពេលខ្លះផលិតផលទាំងនេះត្រូវបាននាំចូលពីប្រទេសជិតខាង ដូច្នេះឱកាសនេះ អ្នកផ្តល់សេវា ឬភ្នាក់ងារអនុវត្តត្រូវតែផ្តល់យោបល់ទៅកសិករ ដើម្បីសម្រេចចិត្តឱ្យច្បាស់លាស់ក្នុងផលិតកម្មរបស់ពួកគាត់តម្រង់ឆ្ពោះទៅកាន់ទីផ្សារ ។ ដើម្បីចៀសវាងជាន់ផលិតកម្មគ្នារវាងសហគមន៍ដាំបន្លែដូចគ្នា អ្នកផ្តល់សេវា ឬភ្នាក់ងារអនុវត្តត្រូវតែកំណត់ប្រភេទបន្លែផ្តាច់មុខ

ណាមួយ សម្រាប់ដំណើរការផលិតកម្ម ដើម្បីជំរុញផលិតផលចូលទៅទីផ្សារ ។ អ្វីដែលអ្នកផ្តល់សេវា ត្រូវចៀសវាងគឺដំណាំតាមរដូវកាល ដែលធ្វើឱ្យសហគមន៍ដំណើរការមិនទៀងទាត់ពេញមួយឆ្នាំ ។ ឧ. សហគមន៍ទី១អាចត្រូវបានកំណត់ឱ្យកសិករដាំស្ពៃ (ស្ពៃខ្មៅ សាឡាត់ ស្ពៃខៀវ ...) ហើយ សហគមន៍ទី២ត្រូវបានកំណត់ឱ្យដាំត្រសក់ ឬសណ្តែកគួរ ឬខាត់ណាជាដើម ។

## *៤.២ ការគ្រប់គ្រង ដឹកនាំ និងចាត់ចែងសហគមន៍*

នៅឆ្នាំដំបូង វគ្គបណ្តុះបណ្តាលគួរត្រូវបានដំណើរការផងដែរ សម្រាប់ផ្តល់គោលគំនិតជាមូលដ្ឋានដល់គណៈគ្រប់គ្រងសហគមន៍អាចអនុវត្តការងារគ្រប់គ្រង និងចាត់ចែងកិច្ចការសហគមន៍ក្នុងកំរិតបឋម ។ ក្រោយពីសហគមន៍មានរចនាសម្ព័ន្ធត្រឹមត្រូវ ការផ្តល់វគ្គនេះរយៈពេល២ ទៅ៣ថ្ងៃ ផ្អែកតាមថវិកា ដែលមាននៅក្នុងគម្រោងថវិកា របស់អនុកិច្ចសន្យាស្រុកឆ្នាំ២០១០ ពិតជាចាំបាច់បំផុត ។ អ្នកផ្តល់សេវា ឬភ្នាក់ងារអនុវត្តត្រូវរៀបចំវគ្គនេះ ដោយសហការជាមួយគណៈកម្មការបច្ចេកទេសស្រុក និងគណៈកម្មការគ្រប់គ្រងគម្រោងអន្តរឃុំ-សង្កាត់ ។ វគ្គនេះមិនគួររៀបចំក្នុងខ្លឹមសារមួយស៊ីជម្រៅខ្លាំងនោះឡើយគឺគ្រាន់តែបង្រៀនពីគោលគំនិតខ្លះៗ និងរបៀបរបប ពិសេសបែបបទគ្រប់គ្រង ដឹកនាំ និងចាត់ចែងក្នុងកំរិតមូលដ្ឋានដល់គណៈគ្រប់គ្រងសហគមន៍ទាំងនោះ ។ វគ្គនេះអាចនឹងតម្រូវបញ្ចូលក្នុងផែនការពង្រឹងសមត្ថភាពបន្ថែមទៀតនៅឆ្នាំទី២ និងទី៣ ដើម្បីធានាកិច្ចការគ្រប់គ្រង ដឹកនាំ និងចាត់ចែងសហគមន៍ប្រព្រឹត្តិទៅដោយរលូន ។

## *៤.៣ នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសហគមន៍*

ផ្អែកតាមបទពិសោធន៍កន្លងមក អ្នកផ្តល់សេវា ឬភ្នាក់ងារអនុវត្តគម្រោងត្រូវរៀបចំនិតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុដ៏សាមញ្ញមួយ សម្រាប់សហគមន៍ទាំងនោះអាចដំណើរការបាន ដោយសហការ និងការពិគ្រោះយោបល់ជាមួយគណៈកម្មការបច្ចេកទេសស្រុក និងគណៈកម្មការគ្រប់គ្រងគម្រោងអន្តរឃុំ-សង្កាត់ ។ និតិវិធីដែលត្រូវរៀបចំនៅឆ្នាំដំបូងនេះគួរផ្តោតលើ របៀបសរសេរលិខិតឆ្លើយឆ្លង របៀបសរសេរកំណត់ហេតុ របៀបសរសេររបាយការណ៍ ការរៀបចំលិខិត ឬទម្រង់គំរូនានាដែលពាក់ព័ន្ធ របៀបរៀបចំសេចក្តីសម្រេចរបស់សហគមន៍ ការរក្សាទុកឯកសារ ការចងក្រងឯកសារ ការកត់ត្រាចំណូល-ចំណាយ របៀបរៀបចំប្រជុំ និងធ្វើលិខិតអញ្ជើញ ការធ្វើរបាយការណ៍ចំណូល-ចំណាយ ... ។ល។ ក្រោយពីរៀបចំនិតិវិធីនេះរួច អ្នកផ្តល់សេវា ឬភ្នាក់ងារអនុវត្តគម្រោងត្រូវផ្សព្វផ្សាយ និងណែនាំគណៈគ្រប់គ្រងសហគមន៍ឱ្យបានដឹង និងបន្តណែនាំជាប្រចាំដោយអនុវត្តវិធីសាស្ត្រ "រៀនបណ្តើរ ធ្វើបណ្តើរ" ។

### ៤.៤ ការនាំនាក់នាំនងទីផ្សារ និងការធ្វើជំនួញខ្នាតតូច

ដើម្បីជម្រុញផលិតផលរបស់កសិករដែលផលិតបានចូលទៅទីផ្សារទាំងក្នុង និងក្រៅស្រុក វគ្គបណ្តុះបណ្តាលនេះពិតជាចាំបាច់ ដែលត្រូវផ្តល់ឱ្យកសិករដែលជាសមាជិកក្នុងសហគមន៍យល់ដឹង ពិសេសគណៈគ្រប់គ្រងសហគមន៍ ។ ការផ្តល់វគ្គបណ្តុះបណ្តាលនេះដល់កសិករគួរធ្វើនៅឆ្នាំទី២ និង ទី៣ ដែលចាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងផែនការរបស់ស្រុក សម្រាប់ការពង្រឹងសហគមន៍ទាំងនោះ ឱ្យរឹងមាំ។ វិធីមួយទៀត នៅពេលសហគមន៍មានថវិកាគ្រប់គ្រាន់ខ្លួនឯងនៅឆ្នាំទី២ឬទី៣ សហគមន៍ អាចចំណាយថវិកាសហគមន៍ផ្ទាល់ដើម្បីជួលអ្នកផ្តល់សេវាផ្នែកនេះរយៈពេល២ ទៅ៣ថ្ងៃ សម្រាប់ ការយល់ដឹង ។ ក្រៅពីនេះ ប្រធានក្រុមប្រឹក្សាភិបាលសហគមន៍សហការជាមួយគណៈកម្មការបច្ចេក ទេសស្រុកស្វែងរកជំនួយគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ឬភ្នាក់ងារអភិវឌ្ឍន៍ ឬមន្ទីរជំនាញខេត្ត ដើម្បីផ្តល់លទ្ធភាពគ្រប់គ្រាន់ សម្រាប់សហគមន៍អាចដំណើរការដោយឯកភាជ្យនៅឆ្នាំទី៤ ឬទី៥ និង ឆ្នាំបន្តបន្ទាប់ទៀត ។

### ៤.៥ ការគ្រប់គ្រងឥណទាន ឬកំចីសហគមន៍

ដោយសារនៅឆ្នាំទី២ សហគមន៍ទទួលបានថវិកាដើមទុន ដែលផ្ទេរពីគណៈកម្មការគ្រប់គ្រង គម្រោងអន្តរឃុំ-សង្កាត់ សម្រាប់បន្តនិរន្តរភាពសហគមន៍ទៅឆ្នាំខាងមុខបន្តបន្ទាប់ទៀត ការប្រើ ប្រាស់ថវិកាអាចនឹងអនុវត្តតាមរូបភាពជាឥណទានដល់សមាជិកសហគមន៍ សម្រាប់ផលិតកម្មរបស់ ពួកគាត់ ។ ម្យ៉ាងទៀត សហគមន៍អាចនឹងខ្ចីប្រាក់ពីស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬធនាគារឯកជន សម្រាប់ ពង្រីកផលទុនសហគមន៍ ក៏ដូចជាពង្រីកទំហំផលិតកម្មរបស់ពួកគាត់នៅឆ្នាំខាងមុខ ។ ដូច្នេះ ការ យល់ដឹងពីការគ្រប់គ្រងឥណទាន ឬកំចីខ្នាតតូចនេះពិតជាសំខាន់ផងដែរ សម្រាប់ជាជំនួយស្មារតី និងការចៀសវាងពីហានិភ័យនានា ដែលកើតឡើងដោយថាហេតុ ពីការផ្តល់ឥណទានដល់សមាជិក របស់ខ្លួន ក៏ដូចជាកំចីប្រាក់ពីខាងក្រៅផងដែរ ។ គណៈកម្មការបច្ចេកទេសស្រុកត្រូវគ្រោងវគ្គនេះ នៅក្នុងផែនការរបស់ស្រុក សម្រាប់ការពង្រឹងសមត្ថភាពសហគមន៍នៅឆ្នាំទី២ និងទី៣ ឬស្រុកអាច ទំនាក់ទំនងជាមួយមន្ទីរជំនាញ ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីស្នើសុំជំនួយបច្ចេកទេសនេះ ។

### ៤.៦ គ្រប់ខណ្ឌច្បាប់ជំនួញខ្នាតតូច

ជាការពិតណាស់ ការអភិវឌ្ឍន៍សហគមន៍មិនត្រឹមតែផ្តោតលើការបណ្តុះបណ្តាល ឬផ្សព្វ ផ្សាយបច្ចេកទេសកសិកម្មដល់កសិករ សម្រាប់ការងារបង្កបង្កើនផលប្រចាំថ្ងៃ ដើម្បីលើកស្ទួយជីវ ភាពពួកគាត់ប៉ុណ្ណោះទេ គោលដៅចុងក្រោយ នៃការអភិវឌ្ឍន៍សហគមន៍នេះគឺជម្រុញ និងពង្រីក វិសាលភាពពីសហគមន៍ឱ្យក្លាយជាសិប្បកម្ម ឬសហគ្រាសខ្នាតតូច-មធ្យម ហើយអាចនឹងឈានដល់

ក្រុមហ៊ុននៅពេលអនាគតដ៏យូរ ដែលទាំងនេះនឹងអាចជួយឱ្យប្រទេសជាតិមានការរីកចំរើន និង សហគមន៍មូលដ្ឋានត្រូវបានពង្រឹង និងអភិវឌ្ឍន៍សមត្ថភាពជាបន្តបន្ទាប់ សម្រាប់ការប្រកួតប្រជែង ពាណិជ្ជកម្ម គុណភាពផលិតកម្ម និងបណ្តាញទីផ្សារ ។ ដូច្នេះ ផ្តើមចេញពីសហគមន៍មូលដ្ឋាន ផលិតកម្មរបស់គាត់នឹងត្រូវពង្រីក និងឈានដល់ទម្រង់ នៃការធ្វើជំនួញខ្នាតតូច រហូតដល់ក្រុមហ៊ុន ផ្គត់ផ្គង់ ឬក៏នាំចេញ ។ ដើម្បីធ្វើឱ្យកសិករ និងថ្នាក់ដឹកនាំសហគមន៍ទាំងនោះអាចឈានឆ្ពោះទៅ គោលដៅចុងក្រោយនោះ ដាច់ខាតចំណេះដឹងផ្នែកច្បាប់ជំនួញនឹងត្រូវផ្តល់ដល់សហគមន៍ទាំងនោះ ដែលជាផ្នែកមួយជួយសម្រួលដល់ការធ្វើជំនួញរបស់ពួកគាត់ នៅពេលសហគមន៍ទាំងនោះបានប្រែ ក្លាយមកជាសហគមន៍ផលិតកម្ម និងការធ្វើជំនួញខ្នាតតូច ។ ក្រុមប្រឹក្សាភិបាលសហគមន៍ សហការ ជាមួយគណៈកម្មការបច្ចេកទេសស្រុក និងក្រុមប្រឹក្សាឃុំទំនាក់ទំនងស្នើសុំជំនួយពីមន្ទីរជំនាញខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលកំពុងធ្វើការពាក់ព័ន្ធវិស័យនេះ ។ ការផ្តល់ចំណេះដឹងផ្នែក ច្បាប់នេះគួរតែបញ្ជ្រាបជាបណ្តើរៗចាប់ពីឆ្នាំទី២ និងឆ្នាំបន្តបន្ទាប់ទៀត រហូតដល់សហគមន៍ទាំង នោះអាចយល់ដឹងច្បាស់លាស់ ។

## V. ការពង្រឹងនិរន្តរភាពសហគមន៍

### ៥.១ ការរៀបចំផែនការពង្រឹងសហគមន៍

ដើម្បីឆ្លើយតបនឹងតម្រូវការសហគមន៍និងការធ្វើឱ្យសហគមន៍រឹងមាំអាចឈានដល់ការគ្រប់ គ្រង ដឹកនាំ និងចាត់ចែងដោយឯករាជ្យ គណៈកម្មការបច្ចេកទេសស្រុក ក៏ដូចជាក្រុមប្រឹក្សាឃុំគួរ លើកផែនការពង្រឹងសមត្ថភាពសហគមន៍ទាំងនោះដោយបញ្ចូលទៅក្នុងផែនការនិងកម្មវិធីវិនិយោគ ឃុំ-សង្កាត់ និងស្រុក ដោយផ្តោតសំខាន់លើការបណ្តុះបណ្តាល ដែលបានលើកឡើងនៅក្នុងផ្នែកទី៤ នៃសេចក្តីណែនាំនេះ ។ ដោយសារស្រុក និងឃុំ-សង្កាត់មានថវិកាប្រចាំឆ្នាំរបស់ខ្លួន ការគាំទ្រទៅ លើសហគមន៍មិនលំបាកឡើយ ។ ដើម្បីឱ្យសហគមន៍អាចរឹងមាំបាន ស្រុក និងឃុំ-សង្កាត់ត្រូវបន្ត ជួយដល់សហគមន៍លើផ្នែកចំណេះដឹងទាំងនោះយ៉ាងហោចណាស់២ឆ្នាំបន្ទាប់ការបង្កើតសហគមន៍ ដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ ។ ក្រៅពីនេះ ស្រុក និងឃុំ-សង្កាត់អាចលើកផែនការនេះស្នើឱ្យមន្ទីរ ជំនាញជុំវិញខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលគាំទ្រ នៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការ ឃុំនៅថ្នាក់ស្រុក-ក្រុង ដែលតែងតែធ្វើជារៀងរាល់ឆ្នាំ ។

### ៥.២ ការគ្រប់គ្រង និងចាត់ចែងថវិកាសហគមន៍

នៅចំណុចទី៣.១ នៃផ្នែកទី៣ នៃសេចក្តីណែនាំនេះបានបញ្ជាក់នូវតួនាទី និងការពាក់ព័ន្ធនា នា របស់គណៈកម្មការគ្រប់គ្រងគម្រោងអន្តរឃុំ-សង្កាត់ និងគណៈកម្មការបច្ចេកទេសស្រុក ក្នុងការ

ចាត់ចែងថវិកាសហគមន៍ ។ តួនាទី និងការពាក់ព័ន្ធលម្អិតនឹងត្រូវចែងនៅក្នុងអនុសារណៈយោគយោគយល់រវាងប្រធានសហគមន៍ និងគណៈកម្មការគ្រប់គ្រងគម្រោងអន្តរឃុំ-សង្កាត់ ក៏ដូចជាគណៈកម្មការបច្ចេកទេសស្រុកផងដែរ ។ ប៉ុន្តែ អ្វីដែលចង់បញ្ជាក់ឱ្យបានច្បាស់លាស់ ក្នុងចំណុចនេះសាជាថ្មីម្តងទៀតគឺថា ថវិកាសហគមន៍នឹងត្រូវចាត់ចែង និងប្រើប្រាស់ជាប្រយោជន៍ដល់សមាជិកសហគមន៍ដោយផ្ទាល់ទៅតាមនិតិវិធីសមស្របមួយ ដែលបានចែងនៅក្នុងអនុសារណៈ និងលក្ខន្តិកៈក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់សហគមន៍ ។ ជាគោលការណ៍ ថវិកានេះនឹងតម្រូវឱ្យសហគមន៍ប្រើប្រាស់ជាទុនសម្រាប់ផលិតកម្មនៅឆ្នាំបន្ទាប់ តាមរូបភាពជាកំចីមានការប្រាក់ ឬគ្មានការប្រាក់អាស្រ័យលើការព្រមព្រៀងក្នុងក្របខ័ណ្ឌសហគមន៍ ។ ក្នុងករណីមានទំនាស់ផលប្រយោជន៍នៅក្នុងសហគមន៍ ហើយមិនអាចសម្របសម្រួល និងដោះស្រាយបាន គណៈកម្មការបច្ចេកទេសស្រុក សហការជាមួយក្រុមប្រឹក្សាឃុំមានសិទ្ធិបង្កក ឬដកហូតថវិកានោះមកគ្រប់គ្រងបណ្តោះអាសន្ន រហូតដល់សហគមន៍នោះដំណើរការរលូនឡើងវិញ។ ក្នុងករណីសហគមន៍ត្រូវបានរំសាយ ថវិកាដើមទុនដែលដកហូតមកគ្រប់គ្រងបណ្តោះអាសន្ននឹងត្រូវប្រើប្រាស់សម្រាប់ការបង្កើតសហគមន៍ថ្មី ដែលនឹងត្រូវចាត់ចែងដោយគណៈកម្មការបច្ចេកទេសស្រុក ។ ចំពោះល័ក្ខខ័ណ្ឌដូចបានបញ្ជាក់ខាងលើនេះនឹងត្រូវបញ្ចូល ទៅក្នុងអនុសារណៈយោគយល់ ក្នុងការផ្ទេរប្រាក់ដើមទុនឱ្យសហគមន៍គ្រប់គ្រងខ្លួនឯងផ្ទាល់ ។

### *៥.៣ ការប្រឹក្សាយោបល់ និងការសម្របសម្រួល*

ទោះបីសហគមន៍នឹងដំណើរការខ្លួនឯងជាបណ្តើរៗចាប់ពីឆ្នាំទី២តទៅ នោះមិនមែនមានន័យថាស្រុក និងឃុំត្រូវផ្តាច់ការទំនាក់ទំនងទាំងស្រុងនោះឡើយ ។ ស្រុក និងឃុំត្រូវចាត់ទុកសហគមន៍ជាសមិទ្ធផលរបស់ខ្លួន និងបន្តសកម្មភាពរបស់ខ្លួនក្នុងការគាំទ្រ ការផ្តល់ប្រឹក្សាយោបល់ និងការសម្របសម្រួលកិច្ចការនានា ដែលសហគមន៍ត្រូវការចាំបាច់ ព្រោះនៅពេលមិនទាន់មានការផ្ទេរសិទ្ធិគ្រប់គ្រងពេញលេញដោយគណៈកម្មការបច្ចេកទេសស្រុក កិច្ចការពាក់ព័ន្ធទាំងនេះនៅតែបន្តធ្វើដដែល ដើម្បីធានាឱ្យសហគមន៍នោះដំណើរការទៅដោយរលូន ។

### *៥.៤ ការដោះស្រាយទំនាស់*

នៅពេលមានទំនាស់ផលប្រយោជន៍ ឬការបែកបាក់នានានៅក្នុងសហគមន៍ គណៈកម្មការបច្ចេកទេស សហការជាមួយក្រុមប្រឹក្សាឃុំមានតួនាទីក្នុងការសម្របសម្រួល និងដោះស្រាយទំនាស់នោះ ទៅតាមលក្ខន្តិកៈ និងច្បាប់ពាក់ព័ន្ធនានារបស់រដ្ឋាភិបាល ។ ក្នុងករណីដោះស្រាយមិនបាន គណៈកម្មការបច្ចេកទេសស្រុកសហការជាមួយក្រុមប្រឹក្សាឃុំរំលាយសហគមន៍នោះ ហើយទំនាស់

នោះនឹងត្រូវបន្តដោះស្រាយតាមផ្លូវតុលាការ នៃព្រះរាជាណាចក្រកម្ពុជា ។ លក្ខខ័ណ្ឌលំអិតនានាទាក់ទងនឹងការដោះស្រាយទំនាស់នឹងត្រូវចែងក្នុងលក្ខន្តិកៈរបស់សហគមន៍ ។

### *៥.៥ ការតាមដាន និងវាយតម្លៃ*

ដើម្បីធានាការអភិវឌ្ឍន៍សហគមន៍សម្រេចបានដល់គោលដៅ ក៏ដូចជាការគ្រប់គ្រង ដឹកនាំ និងចាត់ចែងសហគមន៍ប្រកបដោយតម្លាភាព និងគណនេយ្យភាព គណៈកម្មការបច្ចេកទេសស្រុក និងក្រុមប្រឹក្សាឃុំមានតួនាទីតាមដាន និងវាយតម្លៃរាល់សកម្មភាពរបស់សហគមន៍ទាំងនោះ ពិសេសផ្តោតលើការប្រើប្រាស់ថវិកាដើមទុន ដែលបែងចែកឱ្យកសិករថាតើ ការបែងចែកនោះមានភាពសមធម៌ដែរឬទេ? និងមួយផ្នែកទៀតគឺពិនិត្យមើលពីការរីកចំរើនរបស់សហគមន៍ ដើម្បីរៀនសូត្រជាបទពិសោធន៍ សម្រាប់ការបង្កើតសហគមន៍ថ្មីៗបន្ថែមទៀត បើសិនចាំបាច់ ។ បទពិសោធន៍ដែលទទួលបានពីសហគមន៍ទាំងនោះអាចនឹងត្រូវចែករំលែកដល់ស្រុកដទៃៗទៀត ក៏ដូចជាគណៈកម្មាធិការប្រតិបត្តិ នៃ គ.អ.ជ.ខ កំពង់ចាម ឬខេត្តដទៃៗទៀត ឬក៏ម្ចាស់ជំនួយផ្ទាល់ ។

## VI. ការធ្វើនិយ័តកម្ម និងការពង្រីកទំហំសាលភាព

### *៦.១ ដំណើរការចុះបញ្ជីពាណិជ្ជកម្ម*

ដើម្បីឱ្យសហគមន៍ដំណើរការដោយស្របច្បាប់ ការសម្របសម្រួល និងការរៀបចំការចុះបញ្ជីទទួលស្គាល់ ដោយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងស្ថាប័នមានសមត្ថកិច្ចចាំបាច់ត្រូវធ្វើនៅឆ្នាំទី២ ឬទី៣ ក្រោយពេលសហគមន៍នេះមានរចនាសម្ព័ន្ធច្បាស់លាស់ មានលទ្ធភាពគ្រប់គ្រាន់ក្នុងការបន្តនិរន្តភាព និងមានភាពរឹងមាំជាបណ្តើរៗ ។ កិច្ចការនេះនឹងរៀបចំធ្វើដោយផ្ទាល់ពីគណៈគ្រប់គ្រងសហគមន៍ ដោយមានការគាំទ្របច្ចេកទេស និងការសម្របសម្រួលពីក្រុមប្រឹក្សាឃុំ និងគណៈកម្មការបច្ចេកទេសស្រុក ។ ចំពោះថវិកាចំណាយ សម្រាប់កិច្ចការនេះគឺជាការទទួលខុសត្រូវដោយសហគមន៍ផ្ទាល់ ពោលគឺសមាជិកសហគមន៍អាចចូលរួមតាមរយៈការកាត់អត្រាពន្ធលើផលចំណេញពីផលិតកម្មរបស់ខ្លួន ។ ក្នុងករណី សហគមន៍មិនមានលទ្ធភាព ក្រុមប្រឹក្សាឃុំសហការជាមួយគណៈកម្មការបច្ចេកទេសស្រុកលើកផែនការដាក់បញ្ចូលទៅក្នុងផែនការថវិកាប្រចាំឆ្នាំ របស់ឃុំ ឬស្រុក ដែលជាផ្នែកមួយនៃការពង្រឹងសហគមន៍ផងដែរ ។

### *៦.២ ការផ្ទេរសិទ្ធិគ្រប់គ្រងពេញលេញ*

ក្រោយពីឆ្នាំទី៣ ឬឆ្នាំទី៥ នៅពេលសហគមន៍រឹងមាំ និងអាចដំណើរការដោយឯករាជ្យខ្លួនឯងបាន គណៈកម្មការបច្ចេកទេសស្រុក សហការជាមួយក្រុមប្រឹក្សាឃុំរៀបចំពិធីប្រគល់ការគ្រប់គ្រងពេញសិទ្ធិដល់សហគមន៍ ដោយផ្អែកទៅតាមលក្ខខ័ណ្ឌនានា ដែលបានចែងនៅក្នុងអនុសារណៈ

យោគយល់ តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ ។ ការប្រគល់នេះគឺផ្តោតលើ (១) ការងារគ្រប់គ្រង ដឹកនាំ និងចាត់ចែង (២) ធនធានហិរញ្ញវត្ថុដែលជាប្រាក់ដើមទុន និង (៣) សិទ្ធិប្រតិបត្តិការផលិតកម្មស្របច្បាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ពិសេសការលើកលែងពន្ធលើមុខរបរ ក្នុងកំរិតមួយសមស្រប ។ ខ. ក្រុមប្រឹក្សាឃុំសហការជាមួយគណៈកម្មការបច្ចេកទេសស្រុកស្នើសុំទៅសមត្ថកិច្ចពន្ធដា ដើម្បីលើកលែងពន្ធលើមុខរបររយៈពេល៥ឆ្នាំ ក្រោយពីការប្រកាសការផ្ទេរសិទ្ធិគ្រប់គ្រងទៅឱ្យគណៈគ្រប់គ្រងសហគមន៍ ។ នេះគឺជាចំណែកមួយក្នុងកិច្ចខិតខំប្រឹងប្រែងជួយសហគមន៍នៅគ្រាចុងក្រោយ មុនបញ្ចប់ទាំងស្រុងនូវការទទួលខុសត្រូវ របស់ក្រុមប្រឹក្សាឃុំ និងគណៈកម្មការបច្ចេកទេសស្រុក ។

### ៦.៣ ការពង្រីកវិសាលភាពសហគមន៍

នៅពេលសហគមន៍មានការរីកចំរើន និងមានដើមទុនកាន់តែច្រើន ពិសេសផលទុនផលិតកម្មបានកើនឡើងជាលំដាប់ ការពង្រីកវិសាលភាពសហគមន៍មិនត្រូវបានហាមឃាត់ឡើយ ។ ដូចបានបញ្ជាក់នៅចំណុច ៤.៦ នៃផ្នែកទី៤ គោលដៅចុងក្រោយ នៃការអភិវឌ្ឍន៍សហគមន៍គឺជម្រុញឱ្យមានការផ្លាស់ប្តូរ និងប្រែក្លាយពីសហគមន៍ ទៅជាសិប្បកម្ម ឬសហគ្រាសខ្នាតតូច-មធ្យម និងបន្តរហូតដល់ក្រុមហ៊ុន ។ ដូច្នេះ នៅពេលសហគមន៍ប្រែក្លាយជាដំណាក់កាលបែបនេះ លក្ខណៈនៃផលិតកម្ម រចនាសម្ព័ន្ធ លក្ខន្តិកៈក៏នឹងតម្រូវឱ្យមានការផ្លាស់ប្តូរ និងការធ្វើវិសោធនកម្មផងដែរ ដើម្បីធ្វើឱ្យស្របនឹងលក្ខណៈនៃប្រភេទផលិតកម្មនោះ ។ លក្ខណៈបែបនេះអាចនឹងកើតមានក្នុងរយៈពេលដ៏យូរនៅពេលខាងមុខ ដែលទាមទារឱ្យសហគមន៍ទាំងនោះខិតខំប្រឹងប្រែងជម្រុញផលិតកម្មរបស់ខ្លួនតម្រង់ឆ្ពោះទៅលក្ខណៈផលិតកម្មទ្រង់ទ្រាយធំនិងធ្វើទំនើបកម្មជាបន្តបន្ទាប់កាន់តែប្រសើរឡើង សម្រាប់ការប្រកួតប្រជែង ។ នៅដំណាក់កាលនេះ គណៈកម្មការបច្ចេកទេសស្រុក និងក្រុមប្រឹក្សាឃុំមិនពាក់ព័ន្ធក្នុងការទទួលខុសត្រូវក្នុងការជួយសម្របសម្រួល និងគាំទ្របច្ចេកទេស និងថវិកាទៀតឡើយ ប៉ុន្តែត្រូវតែតាមដានពីភាពប្រែប្រួលនេះ សម្រាប់ចងក្រងជាបទពិសោធន៍ និងការរៀនសូត្រពីភាពជោគជ័យទាំងនោះ ឆ្ពោះទៅការរៀបចំនូវយុទ្ធសាស្ត្រជាក់លាក់ ក្នុងក្របខ័ណ្ឌការអភិវឌ្ឍន៍សហគមន៍ក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន ។

## VII. ការគ្រប់គ្រងបញ្ហាប្រឈម និងហានិភ័យ

| ល.រ | បញ្ហាប្រឈម-ហានិភ័យ | វិធានការបន្ធូរ និងបញ្ចៀស | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| ១ | កសិករមិនចូលរួមក្នុងគម្រោងបែបនេះ | ▪ បង្កើនការយល់ដឹងឱ្យច្បាស់នូវផលប្រយោជន៍ រយៈពេលយូរសម្រាប់សេដ្ឋកិច្ចគ្រួសារ ។ | ▪ ភ្នាក់ងារអនុវត្ត<br>▪ គណៈកម្មការ |

| | | | |
|---|---|---|---|
| | | ▪ អនុវត្តឱ្យពេញលេញនូវជំហាននានា នៃការជ្រើសរើសកសិករជាសមាជិកសហគមន៍ ។<br>▪ ផ្លាស់ប្តូរទីតាំងគម្រោងដ៏សមស្រប | គ្រប់គ្រងគំរោង<br>▪ អាជ្ញាធរមូលដ្ឋាន |
| ២ | កសិករមិនអាចសងប្រាក់ដើមទុនត្រឡប់មកវិញ | ▪ កំណត់ល័ក្ខខ័ណ្ឌច្បាស់លាស់ក្នុងកិច្ចសន្យា<br>▪ អនុគ្រោះ នៅពេលផលិតកម្មបរាជ័យ<br>▪ ជម្រុញការជ្រើសរើសកសិករស្មោះត្រង់<br>▪ ចំណាត់ការតាមផ្លូវច្បាប់របស់រដ្ឋាភិបាល | ▪ គណៈកម្មការគ្រប់គ្រងគម្រោង<br>▪ គណៈគ្រប់គ្រង<br>▪ គ.ប.ស |
| ៣ | សហគមន៍មិនដំណើរការ និងមិនរីកចំរើន | ▪ បង្កើតជំនឿទុកចិត្តក្នុងផលិតកម្ម<br>▪ បង្កើនគុណភាពនៃការផ្តល់សេវាបច្ចេកទេស<br>▪ រៀបចំរចនាសម្ព័ន្ធ និងលក្ខន្តិកៈឱ្យត្រឹមត្រូវ<br>▪ រៀបចំផែនការពង្រឹងសហគមន៍ច្បាស់លាស់<br>▪ រំលាយសហគមន៍ចោល ហើយបង្កើតថ្មី | ▪ គណៈកម្មការគ្រប់គ្រងគម្រោង<br>▪ គ.ប.ស |
| ៤ | មិនមានការគាំទ្រដើម្បីបន្តនិរន្តរភាព | ▪ រៀបចំផែនការពង្រឹងសហគមន៍យ៉ាងតិច ២ឆ្នាំក្រោយពីមានរចនាសម្ព័ន្ធច្បាស់លាស់។<br>▪ ផ្ទេរថវិកាដើមទុនដែលប្រមូលបានពីកសិករឱ្យគណៈគ្រប់គ្រងសហគមន៍គ្រប់គ្រង ...<br>▪ ស្នើសុំមន្ទីរជំនាញ និងអង្គការមិនមែនរដ្ឋាភិបាលជួយគាំទ្រក្នុងសិក្ខាសាលាថ្នាក់ស្រុក | ▪ ក្រុមប្រឹក្សាឃុំ<br>▪ គ.ប.ស |
| ៥ | ការិយាល័យជំនាញថ្នាក់ស្រុកមិនអាចអនុវត្តបាន | ▪ ជម្រុញមន្ទីរជំនាញផ្តល់ការពង្រឹងសមត្ថភាពដល់មន្ត្រីការិយាល័យជំនាញរបស់ខ្លួន ។<br>▪ រៀបចំវគ្គបណ្តុះបណ្តាលតម្រង់ទិស<br>▪ រៀបចំទស្សនៈកិច្ចសិក្សាពីគម្រោងជោគជ័យ | ▪ មន្ទីរជំនាញខេត្ត<br>▪ គ.ប្រ នៃ គ.អ.ជ.ខ<br>▪ ភី.អេស.ឌី.ឌី |
| ៦ | មិនមានតម្លាភាព និងគណនេយ្យភាពនៅក្នុងការគ្រប់គ្រង ដឹកនាំ និងចាត់ចែងសហគមន៍ | ▪ ពង្រឹងយន្តការតាមដាន និងវាយតម្លៃនៅថ្នាក់ស្រុក និងឃុំ ។<br>▪ រៀបចំប្រជុំជាមួយសហគមន៍យ៉ាងតិចមួយលើក ក្នុងមួយខែ ។<br>▪ ណែនាំសហគមន៍ពីការរៀបចំបញ្ជី ឯកសារនានា កំណត់ត្រា និងរបាយការណ៍ហិរញ្ញវត្ថុ<br>▪ កំណត់ពីសិទ្ធិ តួនាទី និងការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងសហគមន៍ និងក្រុមប្រឹក្សាភិបាលឱ្យបានច្បាស់លាស់ ។ | ▪ ភ្នាក់ងារអនុវត្ត<br>▪ គណៈកម្មការគ្រប់គ្រងគំរោង<br>▪ គ.ប.ស<br>▪ គ.ប្រ នៃ គ.អ.ជ.ខ |

| | | | |
|---|---|---|---|
| | | ▪ បង្កើតយន្តការថ្នាក់ខេត្ត ដើម្បីតាមដាន និងវាយតម្លៃលើដំណើរការសហគមន៍ ។ | |
| ៧ | កសិករទទួលប្រាក់ទុនពីគម្រោងមិនព្រមទិញសម្ភារៈ និងពូជសម្រាប់ផលិតកម្ម | ▪ កំណត់លក្ខខ័ណ្ឌច្បាស់លាស់ក្នុងកិច្ចសន្យាពិសេសបង្ហាញពីមុខទំនិញដែលចាំបាច់ទិញ<br>▪ ចាត់វិធានការបណ្តេញចេញពីសមាជិកសហគមន៍ ហើយប្រគល់ជូនសមត្ថកិច្ច ។<br>▪ ជម្រុញការជ្រើសរើសកសិករស្មោះត្រង់<br>▪ អនុវត្តទៅតាមលក្ខខ័ណ្ឌ នៃកិច្ចសន្យា | ▪ គណៈគ្រប់គ្រង<br>▪ គណៈកម្មការគ្រប់គ្រងគំរោង<br>▪ អាជ្ញាធរមូលដ្ឋាន<br>▪ ប៉ូលីសប៉ុស្តឃុំ<br>▪ គ.ប.ស |

## VIII. សុពលភាពនៃសេចក្តីណែនាំ

សេចក្តីណែនាំនេះត្រូវបានផ្តួចផ្តើមគំនិតដំបូងពីលោក **អៀម ពិសិដ្ឋ** ទីប្រឹក្សាតាមដាន វាយតម្លៃ និងវិស័យ ភី.អេស.ឌី.ឌី ប្រចាំខេត្តកំពង់ចាម ដោយមានការពិគ្រោះយោបល់ពីអ្នកពាក់ព័ន្ធជាច្រើន ដែលបានរៀបចំនៅក្នុងក្របខ័ណ្ឌគណៈកម្មាធិការប្រតិបត្តិ នៃ គ.អ.ជ.ខ កំពង់ចាម ។ ថ្នាក់ដឹកនាំ និងមន្ត្រីដែលបានចូលរួមផ្តល់យោបល់លើសេចក្តីណែនាំនេះរួមមាន :

- ឯកឧត្តម **ឯម ដេត** សមាជិកក្រុមប្រឹក្សាខេត្តកំពង់ចាម
- លោកស្រី **ខុច ស៊ុនអេង** អភិបាលរងខេត្ត និងជាអនុប្រធាន គ.ប្រ នៃ គ.អ.ជ.ខ
- លោក **ឡៅម ក៉ន់** សមាជិកអចិន្ត្រៃយ៍ របស់ គ.ប្រ នៃ គ.អ.ជ.ខ
- លោក **ខេង សំណាង** ប្រធានទីប្រឹក្សាកម្មវិធីថ្នាក់ខេត្ត ភី.អេស.ឌី.ឌី
- លោកប្រធាន និងអនុប្រធានផ្នែកទាំង៤ របស់ គ.ប្រ នៃ គ.អ.ជ.ខ
- លោកទីប្រឹក្សារដ្ឋបាលមូលដ្ឋានទាំងអស់ លោកទីប្រឹក្សាគ្រប់គ្រងធនធានធម្មជាតិ និងលើកស្ទួយជីវភាពរស់នៅ និងទីប្រឹក្សាហិរញ្ញវត្ថុ ភី.អេស.ឌី.ឌី ។
- លោក-លោកស្រីជាមន្ត្រីផ្នែកគ្រប់គ្រងកិច្ចសន្យា ហិរញ្ញវត្ថុ និងរដ្ឋបាលមូលដ្ឋាន របស់គណៈកម្មាធិការប្រតិបត្តិ នៃ គ.អ.ជ.ខ កំពង់ចាម ។
- លោក-លោកស្រីអភិបាល និងអភិបាលរងស្រុកទាំង១៣ នៃគោលដៅគម្រោងពង្រឹងតួនាទីថ្នាក់ស្រុក ។
- លោក-លោកស្រីប្រធាន និងអនុប្រធានការិយាល័យពាក់ព័ន្ធថ្នាក់ស្រុកទាំង១៣ នៃគោលដៅគម្រោងពង្រឹងតួនាទីថ្នាក់ស្រុក ។

សេចក្តីណែនាំនេះគ្រាន់តែជាការត្រួសត្រាយផ្លូវលើកដំបូង សម្រាប់ការផ្លាស់ប្តូរយុទ្ធសាស្រ្តអនុវត្តគម្រោងសេវាកម្មបែបសហគមន៍ ដើម្បីធានាឱ្យមានប្រសិទ្ធផល ប្រសិទ្ធភាព និងនិរន្តភាព

នៃលទ្ធផលគម្រោង និងឆ្លើយតបនូវតម្រូវការពិតប្រាកដរបស់គ្រួសារក្រីក្រទទួលបានផលប្រយោជន៍ពីគម្រោងបែបនេះ ។ សេចក្តីណែនាំនេះនឹងត្រូវបានប្រើប្រាស់ជាមគ្គុទេសក៍ និងផែនទីចង្អុលផ្លូវសម្រាប់ភ្នាក់ងារអនុវត្តគម្រោង មន្ទីរ ស្រុក និងអ្នកពាក់ព័ន្ធដទៃទៀត សម្រាប់ការអនុវត្តន៍សាកល្បងនៅឆ្នាំ២០១០ សម្រាប់តែខេត្តកំពង់ចាមប៉ុណ្ណោះ។ លើសពីនេះ សេចក្តីណែនាំនេះមិនត្រូវបានអនុម័ត និងលើកទឹកចិត្តឱ្យអនុវត្តសម្រាប់គម្រោងសហគមន៍នេសាទ សហគមន៍ព្រៃឈើ សហគមន៍អេកូទេសចរណ៍ និងសហគមន៍គ្រប់គ្រងធនធានធម្មជាតិ និងអភិរក្សជីវៈចម្រុះ និងគម្រោងនានានៅក្នុងបណ្តាខេត្តផ្សេងៗទៀតឡើយ ប៉ុន្តែអនុញ្ញាតិឱ្យរៀនសូត្រពីបទពិសោធន៍និងសិក្សាស្វែងយល់អំពីដំណើរការ និងនិតិវិធីនេះ ។ ដំណើរការ និងនិតិវិធីនេះអាចអនុវត្តបានលុះត្រាតែមានការកែសម្រួលឱ្យស្របទៅនឹងលក្ខណៈភូមិសាស្ត្រ និងឥរិយាបថនៃអ្នកអនុវត្ត និងអ្នកទទួលផលប្រយោជន៍ចៀសវាងបញ្ហាប្រឈមដែលកើតឡើងជាយថាហេតុ ដែលអាចប៉ះពាល់ដល់កម្មវិធី គ.ជ.អ.ប ។

ជាការពិតណាស់ សេចក្តីណែនាំនេះបានអនុម័តដោយអង្គប្រជុំគ.ប្រ នាសម័យប្រជុំពីរលើក គឺលើកទី១ នៅថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១០ ក្រោមអធិបតីភាពលោកស្រី ខុង ស៊ុនអេង អភិបាលរងខេត្ត តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម អភិបាលខេត្ត និងជាប្រធាន គ.ប្រ នៃ គ.អ.ជ.ខ ។ កិច្ចប្រជុំលើកទីពីរប្រារព្ធធ្វើនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១០ ក្រោមអធិបតីភាព ឯកឧត្តម ឯម ដេត សមាជិកក្រុមប្រឹក្សាខេត្ត និងលោក ជៀម វ៉ាន់ សមាជិកអចិន្ត្រៃយ៍ របស់ គ.ប្រ នៃ គ.អ.ជ.ខ និងមានការចូលរួមពីលោក-លោកស្រីអភិបាល និងអភិបាលរងស្រុក និងលោក-លោកស្រីប្រធាននិងអនុប្រធានការិយាល័យជំនាញពាក់ព័ន្ធថ្នាក់ស្រុក ព្រមទាំងមន្ត្រីគ.ប្រថ្នាក់ខេត្ត និងទីប្រឹក្សា ភី.អេស.ឌី.ឌី ។

ដើម្បីធានាសុពលភាពសេចក្តីណែនាំ និងដាក់ឱ្យប្រើប្រាស់សាកល្បងក្នុងឆ្នាំ២០១០ នៅកំរិតស្រុក នៃគម្រោងពង្រឹងតួនាទីថ្នាក់ស្រុក និងមន្ទីរដែលប្រើប្រាស់មូលនិធិវិនិយោគខេត្តមានប្រភពពីម្ចាស់មូលនិធិដានីដា ឯកឧត្តម អភិបាលខេត្ត នឹងចេញសេចក្តីជូនដំណឹង ប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ សម្រាប់តែខេត្តកំពង់ចាម និងមានសុពលភាពត្រឹមចុងឆ្នាំ ២០១០ ។ សេចក្តីណែនាំនេះនឹងតម្រូវឱ្យកែសម្រួលចាប់ពីឆ្នាំ ២០១១ បន្ថែមទៀត ដោយផ្អែកតាមមេរៀនពិសោធន៍ ក្នុងឆ្នាំ ២០១០ និងការបត់បែនទៅតាមការប្រែប្រួលរចនាសម្ព័ន្ធរដ្ឋបាលឯកភាពនៅថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យការអនុវត្តន៍គម្រោងបែបនេះប្រព្រឹត្តិទៅដោយរលូន មានប្រសិទ្ធភាពខ្ពស់ និងប្រកបដោយផ្លែផ្កា ។

# ឯកសារភ្ជាប់

## ទម្រង់គំរូនានា

ទម្រង់ទី ១ : បញ្ជីឈ្មោះកសិករស្ម័គ្រចិត្តចូលជាសមាជិកសហគមន៍

ទម្រង់ទី ២.ក : បញ្ជីសំណួរអង្កេតតាមគ្រួសារ

ទម្រង់ទី ២.ខ : តារាងវាយតម្លៃគ្រួសារក្រីក្រ និងគ្រួសារធូរធារដែលបានសម្ភាសន៍

ទម្រង់ទី ៣ : បញ្ជីឈ្មោះសមាជិកសហគមន៍ពេញសិទ្ធិ និងត្រៀមបំរុង

ទម្រង់ទី ៤ : សេចក្តីសម្រេចស្តីពីការបង្កើតក្រុមប្រឹក្សាភិបាលសហគមន៍

ទម្រង់ទី ៥ : សេចក្តីសម្រេចស្តីពីការបង្កើតគណៈគ្រប់គ្រងសហគមន៍

ទម្រង់ទី ៦ : លក្ខន្តិកៈសហគមន៍

ទម្រង់ទី ៧.ក : កិច្ចសន្យាផ្តល់ដើមទុនដល់សមាជិកសហគមន៍ (សម្រាប់ស្រុក)

ទម្រង់ទី ៧.ខ : កិច្ចសន្យាផ្តល់ដើមទុនដល់សមាជិកសហគមន៍ (សម្រាប់មន្ទីរ)

ទម្រង់ទី ៨ : តារាងបញ្ជីពូជ និងសម្ភារៈសម្រាប់ផលិតកម្ម

ទម្រង់ទី ៩.ក : លិខិតបញ្ចប់កិច្ចសន្យារវាងសមាជិកសហគមន៍ និងគណៈកម្មការគ្រប់គ្រងគម្រោង (ស្រុក)

ទម្រង់ទី ៩.ខ : លិខិតបញ្ចប់កិច្ចសន្យារវាងសមាជិកសហគមន៍ និងគណៈកម្មការគ្រប់គ្រងគម្រោង (មន្ទីរ)

ទម្រង់ទី ១០.ក : អនុសារណៈយោគយល់ (សម្រាប់ស្រុក)

ទម្រង់ទី ១០.ខ : អនុសារណៈយោគយល់ (សម្រាប់មន្ទីរ)

ទម្រង់ទី ០ : វិក្កយបត្រទទួលប្រាក់សំណងដើមទុនផលិតកម្ម

ទម្រង់ទី១

# បញ្ជីឈ្មោះកសិករស្ម័គ្រចិត្តចូលជាសមាជិកសហគមន៍..................

| ល.រ | នាម-គោត្តនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | តួនាទីក្នុងគ្រួសារ | ចំនួនអ្នកក្នុងបន្ទុក | មុខរបរចម្បង | អាសយដ្ឋានបច្ចុប្បន្ន | | | ស្ថានភាពគ្រួសារ | ទីតាំងផ្ទះ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ភូមិ | ឃុំ | ស្រុក | | |
| ១ | អ្នកស្រី សុខ ចិន្តា | ស្រី | ១២/០៣/១៩៧០ | មេគ្រួសារ | ៥នាក់ | ធ្វើស្រែ | បែកពាង | ជាលា | បាធាយ | ក្រីក្រ | កណ្ដាលភូមិ |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

បានឃើញ និងឯកភាព

**ប្រធានគណៈកម្មការគ្រប់គ្រងគម្រោង**

ធ្វើនៅ..........ថ្ងៃទី.........ខែ........ឆ្នាំ........

**អ្នកធ្វើតារាង**

ទម្រង់ទី ២.ក

# គណៈកម្មាធិការប្រតិបត្តិ នៃ គ.អ.ជ.ខ កំពង់ចាម
# គណៈកម្មការបច្ចេកទេស នៃ គ.អ.ស ..............

# ព័ត៌មានអង្កេតតាមគ្រួសារ

## I. ព័ត៌មានផ្តល់ឱ្យដោយគ្រួសារសំគ្រចិត្ត

### 1.1 ព័ត៌មានអ្នកផ្តល់បទសម្ភាសន៍ និងស្ថានភាពគ្រួសារ

ឈ្មោះអ្នកផ្តល់បទសម្ភាសន៍ .......................... ភេទ ........ អាយុ ........ឆ្នាំ កើតនៅថ្ងៃទី ..... ខែ ...... ឆ្នាំ ...... រស់នៅភូមិ .................. ឃុំ ............... ស្រុក............. ខេត្ត ............ មុខរបរបច្ចុប្បន្ន ............................ តួនាទីក្នុងគ្រួសារ ........................... ប្រភេទផ្ទះ ............................ រយៈពេលសាងសង់ ...................... ទីតាំងផ្ទះ .............................................................. កំរិតជីវភាពគ្រួសារ ................. កំរិតសិក្សា ........................ ស្ថានភាពសុខភាព ...................... ឈ្មោះបេក្ខជនចូលជាសមាជិកសហគមន៍ .......................... លេខអត្តសញ្ញាណប័ណ្ណ...................... ។

### 1.2 ព័ត៌មានពីសមាជិកគ្រួសារ និងសាច់ញាតិរស់នៅក្នុងបន្ទុក

| ល.រ | នាម.គោត្តនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | សាច់ញាតិ | មុខរបរ | កំរិតសិក្សា | ស្ថានភាពសុខភាព |
|---|---|---|---|---|---|---|---|
| 1 | | | | | | | |
| 2 | | | | | | | |
| 3 | | | | | | | |
| 4 | | | | | | | |
| 5 | | | | | | | |
| 6 | | | | | | | |
| 7 | | | | | | | |
| 8 | | | | | | | |
| 9 | | | | | | | |
| 10 | | | | | | | |
| 11 | | | | | | | |
| 12 | | | | | | | |

ទម្រង់ទី ២.ក

## 1.3 ធនធាន និងទ្រព្យសម្បត្តិ

| ល.រ | ប្រភេទធនធាន | ចំនួន | គិតជាទឹកប្រាក់ | |
|---|---|---|---|---|
| | | | រៀល | ដុល្លារ |
| 1 | ដីភូមិ (ដីឡូតិ៍ផ្ទះ) | | | |
| 2 | ដីស្រែ | | | |
| 3 | ដីចំការ | | | |
| 4 | ចំនួនគោ ឬក្របីញី | | | |
| 5 | ចំនួនគោ ឬក្របីឈ្មោល | | | |
| 6 | ចំនួនជ្រូក និងកូនជ្រូក | | | |
| 7 | ចំនួនមាន់ និងទា | | | |
| 8 | ចំនួនរទេះគោ រទេះអូស | | | |
| 9 | ឧបករណ៍កសិកម្ម | | | |
| 10 | មធ្យោបាយធ្វើដំណើរ (កង់ ម៉ូតូ) | | | |
| 11 | ឧបករណ៍កំសាន្ត (វិទ្យុ ម៉ាញ៉េ) | | | |
| 12 | ឧបករណ៍នេសាទ | | | |
| 13 | ឧបករណ៍ផ្ទះបាយ | | | |
| 14 | សម្ភារៈដំណេក | | | |
| 15 | ផ្សេងៗ (.................) | | | |
| សរុប | | | | |

## 1.4 ប្រភព និងកំរិតចំណូលរបស់គ្រួសារ

| ល.រ | ប្រភពចំណូល | ចំណូលក្នុងឆ្នាំ២០០៩ | | ចំណូលក្នុងឆ្នាំ២០១០ | |
|---|---|---|---|---|---|
| | | រៀល | ដុល្លារ | រៀល | ដុល្លារ |
| 1 | លក់ស្រូវ | | | | |
| 2 | លក់អង្ករ | | | | |
| 3 | លក់អនុផលព្រៃឈើ (ព្រលិត ផ្កាស្មោ.. | | | | |
| 4 | លក់បន្លែ ផ្លែឈើ | | | | |
| 5 | លក់ត្រី | | | | |
| 6 | លក់មាន់ ទា | | | | |
| 7 | លក់គោ ក្របី និងសត្វស្រុកផ្សេងទៀត | | | | |
| 8 | លក់កំលាំងពលកម្ម (កំរៃឈ្នួលពលកម្ម) | | | | |

ទម្រង់ទី ២.ក

| | | | | | |
|---|---|---|---|---|---|
| 9 | លក់ដីស្រែ ចំការ ដីភូមិ | | | | |
| 10 | ជំនួយពីកូន បងប្អូន សាច់ញាតិ | | | | |
| 11 | អំណោយពីសប្បុរសជន | | | | |
| 12 | កំចីជាសាច់ប្រាក់ | | | | |
| 13 | កំចីជាស្បៀង និងវត្ថុមានតម្លៃ | | | | |
| 14 | ផ្សេងៗ (.......................) | | | | |
| **សរុបរង** | | | | | |
| **សរុបរួម (ជាដុល្លារទាំងអស់)** | | | | | |

## 1.5 ប្រភព និងកំរិតចំណាយរបស់គ្រួសារ

| ល.រ | ប្រភពចំណូល | ចំណាយក្នុងឆ្នាំ២០០៩ | | ចំណាយក្នុងឆ្នាំ២០១០ | |
|---|---|---|---|---|---|
| | | រៀល | ដុល្លារ | រៀល | ដុល្លារ |
| 1 | ម្ហូបចំណី (ត្រី សាច់ បន្លែ គ្រឿងទេស...) | | | | |
| 2 | អង្ករ និងស្រូវ | | | | |
| 3 | គ្រឿងប្រើប្រាស់ក្នុងផ្ទះ (ចានឆ្នាំង ចង្រ្កាន...) | | | | |
| 4 | ទិញសម្ភារៈ (ម៉ូតូ កង់ វិទ្យុ ទូរទស្សន៍...) | | | | |
| 5 | ពូជស្រូវ ដំណាំ សត្វ | | | | |
| 6 | ការតុបតែងខ្លួន និងសំលៀកបំពាក់ | | | | |
| 7 | ចំណាយកូនទៅរៀន | | | | |
| 8 | ពិធីសង្គម (បុណ្យ មង្គលការ ជប់លាង...) | | | | |
